# របាយការណ៍ប្រទេសកម្ពុជា

## រៀបរៀងដោយ លោកស្រី ធីតា ឃឹះ

## នាយិកាសីលការ

**អក្សរកាត់**

**សមាគមអភិវឌ្ឍន៍ និងសិទ្ធិមនុស្សកម្ពុជា**

ADHOC- Cambodian Human Rights and Development Association

**ក្រុមប្រឹក្សាដើម្បីកំណែទម្រង់រដ្ឋបាល**

CAR- Council for Administration Reform

**ក្រុមប្រឹក្សាធម្មនុញ្ញ**

CC- Constitutional Council

**ការស្ទាបស្ទង់ប្រជាសាស្ត្រ និងសុខភាពកម្ពុជា**

CDHS- Cambodia Demographic and Health Survey

**សន្ធិសញ្ញា ដើម្បីលុបបំបាត់ការរើសអើងគ្រប់រូបភាពប្រឆាំងនឹងស្ត្រី**

Convention for the Elimination of All Forms of Discrimination Against Women

**មជ្ឈមណ្ឌលស្ត្រីកម្ពុជាមានវិបត្តិ**

CWCC- Cambodian Women Crisis Center

**យែនឌ័រ និងការអភិវឌ្ឍន៍សំរាប់កម្ពុជា**

GAD - Gender and Development for Cambodia

**មជ្ឈមណ្ឌលសំលេងស្ត្រីខ្មែរ**

Khmer Women's Voice Center

**គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍**

MDGs – Millennium Development Goals

**ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន**

MOWVA – Ministry of Women's and Veterans' Affairs

**រដ្ឋសភា**

NA – National Assembly

**ក្រុមប្រឹក្សាជាតិ នៃស្ត្រី**

NCW- National Council of Women

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

NEC – National Election Committee

**វេទិកាអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា**

NGO Forum - The Non-Governmental Organization on Cambodia

**អាជ្ញាធរអង្គការសហប្រជាជាតិបណ្តោះអាសន្នប្រចាំកម្ពុជា**

UNTAC – United Nations Transitional Authority in Cambodia

**អង្គការចំរើនស្ត្រី**

WFP – Women for Prosperity

# មាតិកា


១-សេចក្តីផ្តើម......១

២-វិធីសាស្ត្រ......២

៣-គំហើញ......៣

៣.១. សេវាសាធារណៈ និងគោលនយោបាយ......កំហុសឆ្គង ឯកសារមិនមានការបញ្ជាក់

៣.១.១ អត្រានៃស្ត្រី និងបុរស ដែលបានតែងតាំង/បោះឆ្នោតជ្រើសរើសសំរាប់តួនាទីក្នុងរដ្ឋាភិបាល (ពីថ្នាក់ស្រុកដល់ថ្នាក់ជាតិ)......២

៣.១.១.១.នីតិប្បញ្ញត្តិកម្ពុជា......២

១. ស្ត្រីដែលត្រូវបានបោះឆ្នោតជ្រើសរើសជាតំណាងក្នុងសភាជាតិ កាលពី ១២ ឆ្នាំមុន......៤

២-ឧបសគ្គចំពោះស្ត្រីក្នុងការទទួលបានសំលេងឆ្នោតដើម្បីទទួលបាននូវការងាររដ្ឋ......៤

ក. កត្តាសង្គម និងវប្បធម៌......៤

ខ. ផលប៉ះពាល់ដល់ស្ត្រី......៤

គ. ប្រព័ន្ធនយោបាយកម្ពុជា......៥

៣.១.១.២.អង្គតុលាការ......៧

៣.១.១.៣.អង្គនីតិប្រតិបត្តិ......៩

៣.១.២ អត្រានៃចំនួនស្ត្រីក្នុងចំណោមអ្នកបំរើសេវាសាធារណៈតាមកំរិតនីមួយៗ (បុគ្គលិករដ្ឋបាលផ្នែកបច្ចេកទេស អ្នកគ្រប់គ្រង)......១០

៣.១.៣.បញ្ហា/ការលំបាកដែលស្ត្រីបានជួបប្រទះនៅក្នុងសេវាសាធារណៈ/តួនាទីរដ្ឋ......១០

៣.២ ភាពជាអ្នកដឹកនាំរបស់ស្ត្រីនៅក្នុងអង្គការនានា......១១

៣.២.១ ការប្រៀបធៀបភាគផលរវាងស្ត្រី និងបុរស ក្នុងភាពជាអ្នកដឹកនាំនៅក្នុងអង្គការមិនមែនរដ្ឋាភិបាល......១១

៣.២.២ ការប្រៀបធៀបភាគផលរវាងស្ត្រី និងបុរស ក្នុងភាពជាអ្នកដឹកនាំនៃសហជីពកម្មករ......១២

៣.២.៣ការប្រៀបធៀបនូវភាគផលរបស់ស្ត្រីក្នុងភាពជាអ្នកដឹកនាំក្នុងស្ថាប័នអប់រំ......១៣

៣.២.៤ ការប្រៀបធៀបភាគផលរវាងស្ត្រីនិងបុរសក្នុងភាពជាអ្នកដឹកនាំក្នុងសហករណ៍......១៤

៣.២.៥ ការប្រៀបធៀបភាគផលករបស់ស្ត្រី ក្នុងភាពជាអ្នកដឹកនាំនៃមុខជំនួញខ្នាតតូច......១៥

៣.២.៦ បញ្ហា/និងការលំបាកដែលស្ត្រីជួបប្រទះក្នុងភាពជាអ្នកដឹកនាំនៅក្នុងអង្គការផ្សេងគ្នា......១៥

៣.៣ ការចូលរួមរបស់ស្ត្រីនៅក្នុងគោលនយោបាយការបោះឆ្នោត.....១៥
៣.៣.១ សិទ្ធិស្របច្បាប់របស់ស្ត្រីក្នុងការបោះឆ្នោត.....១៥
៣.៣.២ សមាមាត្រអ្នកបោះឆ្នោតជាស្ត្រី ទៅនឹងអ្នកបោះឆ្នោតជាបុរស.....១៥
៣.៣.៣ សមាមាត្របេក្ខនារី និងបេក្ខបុរស.....១៦
៣.៣.៤ សមាមាត្រភាពជាអ្នកដឹកនាំរបស់ស្ត្រីប្រៀបធៀបនឹងបុរសនៅក្នុងគណបក្សនយោបាយ.....១៦
៣.៣.៥ បញ្ហា/ការលំបាកនៃស្ត្រីនៅក្នុងការចូលរួមរបស់ពួកគេក្នុងគោលនយោបាយនៃការបោះឆ្នោត.....១៦
៣.៤ សកម្មភាពជួយជនងាយរងគ្រោះ.....១៧
៣.៥ ក្រុមស្ត្រីដែលត្រូវបានគេរើសអើង.....១៧
៣.៥.១ ស្ត្រីជនជាតិដើម.....កំហុសឆ្គង! ឯកសារមិនមានការបញ្ជាក់
៣.៥.២ ស្ត្រីក្នុងជំលោះប្រដាប់អាវុធ.....១៧
៣.៥.៣ អំពើហិង្សាប្រឆាំងនឹងស្ត្រី.....១៨
៣.៥.៤ ការពិភាក្សាលើគោលនយោបាយ និងការអនុវត្តន៍របស់ពួកគេ.....១៨
ឯកសារយោង.....២១
បញ្ជីឈ្មោះអ្នកដែលបានធ្វើបទសំភាសន៍.....២១

## ១. សេចក្តីផ្តើម

ចំនួនប្រជាជននៅប្រទេសកម្ពុជាក្នុងឆ្នាំ ២០០១មានចំនួន ១៣.១ លាននាក់ ហើយគេប៉ាន់ប្រមាណ នឹង កើនដល់ ១៦.៦លាន នាក់ ក្នុងឆ្នាំ ២០០៦ ។ ៥២% នៃចំនួនប្រជាជនទាំងអស់ជាស្ត្រី ។ យើងគួរចាប់អារម្មណ៍ផងដែរថា ក្នុងរយៈពេលពីរ ទសវត្សរ៍ បន្ទាប់ពីសង្គ្រាមស៊ីវិល ទារកបានកើតឡើងយ៉ាងសន្ធឹកសន្ធាប់ក្នុងឆ្នាំ១៩៨០ ។ ដូច្នេះ នៅក្នុងប្រទេសកម្ពុជាសព្វថ្ងៃ ចំនួនប្រជាជន ៥៦% គឺជាមនុស្សមានអាយុក្រោម ២០ឆ្នាំ ។ សង្គ្រាមមិនគ្រាន់តែបានកម្ទេច តែរូបភាពខាងក្រៅនោះ ទេ ប៉ុន្តែវាបានកម្ទេចនូវហេដ្ឋារចនាសម្ព័ន្ធសង្គម ដែលបានបន្សល់ទុក ភាពដ៏ធ្ងន់ធ្ងរទៅលើប្រជាជនកម្ពុជា ។ ចំនួន២៥% ដែលជាស្ត្រីមេគ្រួសារ មានភាពក្រីក្រជាងគេនៅក្នុងប្រទេស ។ អត្រានៃភាពក្រីក្រទូទៅមាន ៣៦% និងចំនួន៩០% នៃអ្នកក្រ រស់នៅតំបន់ជនបទ ។ នៅក្នុងសង្គមកម្ពុជា ស្ត្រីត្រូវបានគេចាត់ទុកថា មានឋានៈទាបជាងបុរស ទោះបីជា ពួកគេជាអ្នកបញ្ចេញកម្លាំងពលកម្មច្រើនលើសលប់យ៉ាងណាក៏ដោយ ។ អត្រាស្ត្រីពលករខ្មែរមានចំនួន ៨២% ដែលជាចំនួន មួយច្រើនលើសលប់ក្នុងចំណោមប្រទេសនៅអាស៊ីអាគ្នេយ៍ ។

**តារាង ១**- ការផ្តល់សិទ្ធិអំណាចដល់ស្ត្រី : គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍នៅកម្ពុជា

| **សន្ទស្សន៍គន្លឹះ** | **តំលៃ** | **ឆ្នាំ** | **២០០៥** | **២០១០** | **២០១៥** |
|---|---|---|---|---|---|
| កាត់បន្ថយភាពខុសគ្នានៃយែនឌ័រក្នុងការអប់រំកំរិតមធ្យមសិក្សា | ៤៨ | ២០០១ | ៥៩ | ៨០ | ១០០ |
| កាត់បន្ថយភាពខុសគ្នានៃយែនឌ័រក្នុងការអប់រំកំរិតឧត្តមសិក្សា ឬមហាវិទ្យាល័យ | ៣៨ | ២០០១ | ៥០ | ៧០ | ១០០ |
| លុបបំបាត់នូវភាពខុសគ្នានៃយែនឌ័រក្នុងការទទួលប្រាក់ឈ្នួលនៅគ្រប់វិស័យសេដ្ឋកិច្ចទាំងអស់ | | | | | |
| ភាគផលនៃប្រាក់ឈ្នួលរបស់ស្ត្រីនៅក្នុងកសិកម្ម | ៣៥ | ១៩៩៨ | ៥០ | ៥០ | ៥០ |
| ភាគផលប្រាក់ឈ្នួលស្ត្រីនៅក្នុងឧស្សាហកម្ម | ៤៤ | ១៩៩៨ | ៥០ | ៥០ | ៥០ |
| ភាគផលនៃប្រាក់ឈ្នួលស្ត្រីនៅក្នុងសេវាផ្សេងៗ | ២១ | ១៩៩៨ | ៣០ | ៣៧ | ៥០ |
| ការលុបចោលនូវភាពខុសគ្នានៃយែនឌ័រក្នុងស្ថាប័នរដ្ឋាភិបាល | | | | | |
| សមាមាត្រអាសនៈនៅក្នុងរដ្ឋសភាជាតិ | ១២ | ២០០៣ | ១៧ | ២៤ | ៣០ |
| សមាមាត្រអាសនៈនៃស្ត្រីនៅក្នុងព្រឹទ្ធសភា | ១៣ | ២០០៣ | ១៧ | ២៤ | ៣០ |
| សមាមាត្រនៃស្ត្រីដែលជារដ្ឋមន្ត្រី | ៨ | ២០០៣ | ៩ | ១២ | ១៥ |
| សមាមាត្រនៃស្ត្រីដែលជារដ្ឋលេខាធិការ | ៦ | ២០០៣ | ៨ | ១៥ | ១៨ |
| សមាមាត្រនៃស្ត្រីដែលជាអភិបាលខេត្ត | ០ | ២០០៣ | ៤ | ៨ | ១៥ |

| | | | | | |
|---|---|---|---|---|---|
| ការកាត់បន្ថយអំពើហឹង្សាគ្រប់រូបភាពលើស្ត្រី | | | | | |
| ភាគរយនៃប្រជាជនដែលដឹងថាអំពើហឹង្សាប្រឆាំងនឹងស្ត្រីគឺជាអាកប្បកិរិយាខុសទាំងស្រុងនិងជាអំពើឧក្រិដ្ឋកម្ម ។ | អត់មានតួលេខ | អត់មានតួលេខ | ២៥ | ៥០ | ១០០ |

រាជរដ្ឋាភិបាលកម្ពុជាមានការប្រឈមមុខជាច្រើន ក្នុងការខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីជួយធ្វើឱ្យមាន យែនឌ័រក្នុងវិស័យអប់រំ ។ អន្តរាគមន៍របស់រដ្ឋាភិបាលធ្វើឡើងក្នុងទម្រង់ជាគំរោងកសាងហេដ្ឋារចនាសម្ព័ន្ធ ដែលអាចមើល ឃើញដូចជាសំណង់អាគារ បង្គន់ បន្ទប់ស្នាក់នៅ និងការផ្តល់ឱ្យនូវអាហារូបករណ៍ ដើម្បីឱ្យក្មេងស្រីអាចស្នាក់នៅបន្តការសិក្សា ។ ទោះបីជាយ៉ាងណាក៏ដោយ វិធានការទាំងនេះមិនទាន់បានដោះស្រាយនូវគម្លាតវប្បធម៌ ដែលធ្វើឱ្យសង្គមចង់បញ្ជូនក្មេងប្រុសច្រើនជាងក្មេងស្រីទៅសាលារៀន ។ ការផ្សារភ្ជាប់គម្លាតក្នុងសេវាសាធារណៈ ក៏ជាបញ្ហាមួយផងដែរហើយរបាយការណ៍នេះនឹងរៀបរាប់ ព្រមទាំងវិភាគលើបញ្ហាទាំងនេះដូចខាងក្រោម។

## ២. វិធីសាស្ត្រ

ក្នុងការសរសេររបាយការណ៍នេះ ជំហានដូចខាងក្រោមត្រូវបានយកមកអនុវត្ត :

១-ប្រមូល និងសិក្សានូវឯកសារដែលមានស្រាប់

២-ធ្វើបទសម្ភាសន៍ជាមួយនឹងអ្នកពាក់ព័ន្ធសំខាន់ៗ នៅក្នុងវិស័យដែលពួកគេសកម្មនឹងយល់ដឹងទៅលើសន្ធិសញ្ញាលុបបំបាត់ការរើសអើងគ្រប់រូបភាព ប្រឆាំងនឹងស្ត្រី និងទៅលើស្ថានភាពរបស់ស្ត្រី ។

៣-ធ្វើបទសម្ភាសន៍ ជាមួយសមាជិកក្រុមប្រឹក្សាឃុំ ចំនួន៥ ឃុំ ក្នុងស្រុកមួយ ក្នុងខេត្ត កំពង់ចាម ។

៤. រួមទាំងការសង្ខេប និងវិភាគទិន្នន័យ

## ៣. គំហើញ

### ***<u>សេវាសាធារណៈ និងគោលនយោបាយ</u>***

បន្ទាប់ពីជាងពីរទសវត្សរ៍នៃជម្លោះក្នុងស្រុក និងការធ្វើអន្តរាគមន៍បន្តបន្ទាប់មួយនៅឆ្នាំ ១៩៩៣ ពី អង្គការសហប្រជាជាតិ ប្រទេសកម្ពុជាបានទទួលយកប្រព័ន្ធពហុបក្សជាមួយនឹងការបោះឆ្នោតជារៀងរាល់៥ឆ្នាំម្តងដើម្បីជ្រើសរើសតំណាងសភាជាតិ។

រដ្ឋធម្មនុញ្ញកម្ពុជាបានចែងឱ្យមានអង្គ៣: អង្គនីតិប្រតិបត្តិ នីតិប្បញ្ញត្តិ និងអង្គតុលាការ។ ព្រះមហាក្សត្រ (គ្មានអំណាចប្រត្តិបត្តិទេ) តែដឹកនាំព្រះរាជាណាចក្រកម្ពុជា ។

អង្គនីតិប្បញ្ញត្តិ មានសមាជិកសភា ១២៣ រូប ។ រដ្ឋធម្មនុញ្ញត្រូវបានធ្វើការកែប្រែនៅឆ្នាំ ១៩៩៩ ដោយបន្ថែមអង្គមួយទៀតដែលខ្ពស់ជាងរដ្ឋសភា គឺព្រឹទ្ធសភា ជាមួយនឹងការជ្រើសតាំងសមាជិក ៦១ នាក់ ដែលមកពីគណបក្សនយោបាយទាំងឡាយនៅក្នុងរដ្ឋសភា ។ អំណាចកំពូលដែលជាក្រុមប្រឹក្សាធម្មនុញ្ញ គឺជាស្ថាប័នតែមួយគត់ដែលមានតួនាទីបកស្រាយច្បាប់រដ្ឋធម្មនុញ្ញ ។

ទឹកដីកម្ពុជាចែកចេញជា ២៤ ខេត្ត និង ១៨៧ ស្រុក ឬខណ្ឌ ។ នៅក្នុង ១៨៧ ស្រុក ឬខណ្ឌ នេះចំណុះទៅដោយ ១,៦២១ ឃុំ។

**អត្រានៃចំនួនស្ត្រី និងបុរស ដែលបានបោះឆ្នោតជ្រើសរើស/និងតែងតាំងទទួលតួនាទីរដ្ឋាភិបាល (ពីថ្នាក់ស្រុកដល់ថ្នាក់ជាតិ )**

**ក-នីតិបញ្ញត្តិ**

| **ស្ថាប័ន** | **តួនាទី និងអំណាច** | **ស្ថានភាពនៃអំណាចស្ត្រី** |
|---|---|---|
| **១.ក្រុមប្រឹក្សាធម្មនុញ្ញ** | **ក្រុមប្រឹក្សាធម្មនុញ្ញ** គឺជាអង្គនីតិបញ្ញត្តិកំពូល ដែលតួនាទីរបស់គេគឺធ្វើការបកស្រាយ ច្បាប់រដ្ឋធម្មនុញ្ញចុងក្រោយរបស់ប្រទេស ។ ក្រុមប្រឹក្សាធម្មនុញ្ញ គឺជាអង្គភាពមួយដែលពិនិត្យឡើងវិញនូវច្បាប់ទាំងឡាយដែលអនុម័តដោយរដ្ឋ សភានិងព្រឹទ្ធសភា ដើម្បីធ្វើឱ្យប្រាកដថាច្បាប់ទាំង នោះស្របទៅតាមរដ្ឋធម្មនុញ្ញ។ ក្រុមប្រឹក្សាធម្មនុញ្ញ មានអាណត្តិ ៩ឆ្នាំមានសមាជិក ៩រូប ដោយមានការផ្លាស់ប្តូរសមាជិករៀងរាល់៣ឆ្នាំ ក្នុងចំណោម សមាជិកទាំងនោះ ។ | គ្មានស្ត្រីម្នាក់សោះមានតួនាទីនៅក្នុងក្រុមប្រឹក្សាធម្មនុញ្ញ ។ |
| **២ .សភាជាតិ** | រដ្ឋសភាបានចាប់ផ្តើមក្នុងខែ មិថុនា ឆ្នាំ១៩៩៣ ដែលមានការគាំទ្រពីអាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិនៅកម្ពុជា ( អ៊ុនតាក់ ) ។ អ៊ុនតាក់បានរៀបចំការបោះឆ្នោតលើកទីមួយក្នុងខែមិថុនា ឆ្នាំ១៩៩៣ បន្ទាប់ពីមានកិច្ចព្រមព្រៀងក្រុងប៉ារីសក្នុងឆ្នាំ ១៩៩១ បន្ទាប់ពីការបោះឆ្នោតជាតិមួយដែលមាន លក្ខណៈពហុបក្ស ដោយមានការប្រកួតប្រជែងពីគណបក្សផ្សេងៗរួចមក រដ្ឋាភិបាលមួយត្រូវបានកើតឡើង។ | ***សមាជិកសរុបមានពី១២០ ទៅ ១២២ នាក់ពីឆ្នាំ១៩៩៣ ដល់ ២០០៣ ។ យើងសង្កេតមានភាពប្រសើរឡើង ពីចំនួនស្ត្រីដែលបានទទួលសន្លឹកឆ្នោត ដើម្បីធ្វើការក្នុងរដ្ឋសភាក្នុងរយៈពេល ១២ឆ្នាំកន្លងមកហើយនេះ។*** |

| | | |
|---|---|---|
| **៣-ព្រឹទ្ធសភា** | ព្រឹទ្ធសភាបានបង្កើតឡើងក្នុងឆ្នាំ ១៩៩៩ ដើម្បីផ្តល់ឱ្យមានតុល្យភាពក្នុងការបង្កើតច្បាប់ ។ ព្រឹទ្ធសភាគឺជាស្ថាប័ននីតិបញ្ញត្តិកំរិតខ្ពស់ ។ ការជ្រើសតាំងសមាជិកព្រឹទ្ធសភាត្រូវបានធ្វើឡើងដោយគណបក្សនយោបាយនៅក្នុងរដ្ឋសភា ហើយ និងព្រះមហាក្សត្រ ដោយសមាមាត្រ ទៅនឹងចំនួនអាសនៈនៅក្នុងសភាជាតិ។ ព្រះមហាក្សត្រមានអំណាចតែងតាំងសមាជិក ២រូប ក្នុងព្រឹទ្ធសភា ។ ចាប់តាំងពីការកកើតឡើងនៃព្រឹទ្ធសភា មានការជំទាស់ទៅលើច្បាប់ដែលអនុម័តដោយរដ្ឋសភាតែម្តងប៉ុណ្ណោះ ។ ព្រឹទ្ធសភាត្រូវបានគេកំណត់ឱ្យមាន ការបោះឆ្នោតក្នុង២០០៣ ប៉ុន្តែធម្មនុញ្ញសំរាប់ការបោះឆ្នោត ព្រឹទ្ធសភា មិនទាន់បានធ្វើសេចក្តីព្រាងនៅឡើយទេ។ | ក្នុងចំណោមសមាជិកព្រឹទ្ធសភា ៦១ នាក់ ១៣ ភាគរយគឺជាស្ត្រី ។ |
| **៤.ក្រុមប្រឹក្សាឃុំ-សង្កាត់** | ឃុំចំនួន ១,៦២១ ត្រូវបានគេធ្វើវិមជ្ឈការ ដែលជាផ្នែកមួយនៅក្នុងការកំណែទំរង់ ក្នុងលទ្ធិប្រជាធិតេយ្យក្នុងឆ្នាំ ២០០២ ។ ឃុំទាំងនោះ ធ្វើប្រត្តិបត្តិការជាបែបផែនរដ្ឋបាលថ្នាក់មូលដ្ឋាន ។ ក្រុមប្រឹក្សាឃុំសង្កាត់នីមួយៗមានសមាជិកពី ៥ ទៅ ១១នាក់ ។ សមាជិកក្រុមប្រឹក្សាឃុំសង្កាត់ត្រូវបានកំណត់ ដោយយោងទៅតាមរូបមន្តដែលផ្អែកទៅលើចំនួនមនុស្សនៅក្នុងឃុំ ។ ក្នុងខែកុម្ភៈ ឆ្នាំ ២០០២ ស្ត្រី ៥០.៤៤ ភាគរយ បានទៅបោះឆ្នោត ដើម្បីជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់របស់គេ ។ | ស្ត្រី ៩៧៧ នាក់ ដែលតំណាងឱ្យ ៩ភាគរយនៃចំនួនសរុបនៃសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ ត្រូវបានគេបោះឆ្នោតនៅក្នុងឃុំចំនួន ១៦២១ ទូទាំងប្រទេស ។ មានសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ទាំងអស់ចំនួន១១,២៨៣ ។ |

## ចំនួនស្ត្រីដែលជាប់ឆ្នោតនៅក្នុងសភាជាតិ  កាលពី១២ឆ្នាំកន្លងទៅនេះ  :

**រូបទី១: ស្ត្រីនៅក្នុងព្រឹទ្ធសភា (ដែលបានតែងតាំង)**




*ប្រភព: ក្រសួងមហាផ្ទៃ*

## ឧបសគ្គចំពោះការបោះឆ្នោតរបស់ស្ត្រីដើម្បីកាន់ដំណែង

**ក. <u>ផ្នែកវប្បធម៌ និងសង្គម</u>**

នៅប្រទេសកម្ពុជា ស្ត្រីមិនត្រូវបានគេពិចារណាឱ្យបានជិតដល់ ចំពោះការកាន់កាប់ និងទទួលខុស ត្រូវលើតំណែងសាធារណៈ ជាពិសេសនៅក្នុងវិស័យនយោបាយ ។ គេគិតថា ការងារនយោបាយពោរពេញទៅដោយអំពើហឹង្សា និងឧបាយកលកខ្វក់ ដែលស្ត្រីមិនអាចដោះស្រាយបាន។ រហូតមកដល់សព្វថ្ងៃ អំពើហឹង្សាបានផ្សាភ្ជាប់ទៅជាមួយនឹងនយោបាយ ។ ដូច្នេះហើយការងារនេះសមរម្យសំរាប់តែបុរសខែងរែងតែប៉ុណ្ណោះ ។

តំណែងនៃការទទួលខុសត្រូវធំៗ ត្រូវបានគេគិតថា មានភាពធ្ងន់ធ្ងរខ្លាំងពេកសំរាប់ស្ត្រី ដែលធម្មតាគួរតែទទួលខុសត្រូវតែទៅលើការងារក្នុងផ្ទះ និងមើលថែកូន។ ធ្វើការក្រៅផ្ទះ ការផ្សងព្រេងនៅក្នុងសង្គម មិនត្រូវគេមើលឃើញថាជាអទិភាពសំរាប់ស្ត្រីទេ។

នៅពេលយប់ ស្ត្រីមិនអាចចេញក្រៅ បើសិនគេដើរទៅខាងក្រៅ ពួកគេត្រូវតែនៅជិតៗផ្ទះ ព្រោះនៅប្រទេសកម្ពុជា មានហេតុការណ៍ពុំប្រក្រតីយនិងគ្មានច្បាប់ទំលាប់កើតឡើងជាច្រើន។ បន្ទាប់ពីរទសវត្សនៃសង្គ្រាមស៊ីវិលកន្លងមក សន្តិសុខគឺនៅតែជាការព្រួយបារម្ភដ៏ចម្បងមួយសំរាប់ស្ត្រី ហើយទប់ស្កាត់ស្ត្រីភាគច្រើនពីការចេញទៅក្រៅម្នាក់ឯងនៅក្នុងសហគមន៏ ឬការនិយាយជាសាធារណៈ។

ស្ត្រីមិនត្រូវបានគេគិតថា អាចដោះស្រាយបញ្ហាតានតឹង ដែលអ្នកដឹកនាំត្រូវតែទទួលប្រឈមមុខជានិច្ចជាកាលដើម្បីបំរើការនៅក្នុងការិយាល័យសាធារណៈ ជាមួយនឹងការប្រកួតប្រជែងយ៉ាងខ្លាំង ដែលមិនអាចបំបែកបានពីការងារនយោបាយ។ ទីបញ្ចប់ ស្ត្រីត្រូវបានគេជឿថា មិនត្រូវមានការអប់រំមូលដ្ឋានគ្រប់គ្រាន់ក្នុងការកាន់កាប់តំណែងក្នុងសង្គមជាពិសេសក្នុងការិយាល័យសាធារណៈ។

## ផលប៉ះពាល់ចំពោះស្ត្រី

ជាមួយនឹងបរិស្ថានវប្បធម៌ វាមិនគួរឱ្យភ្ញាក់ផ្អើលទេ ដែលស្ត្រីជាច្រើនបានជឿថា ពួកគេពុំស័ក្តិសម កាន់កាប់តំណែងសាធារណៈ និងពុំមានសមត្ថភាព ដើម្បីចូលរួមក្នុងការប្រកួតប្រជែង នយោបាយឡើយ ។

ព្រោះតែជំនឿនេះ និងការទាមទារអំពីតួនាទីដ៏តឹងរឹងលើស្ត្រី នោះធម្មតាស្ត្រីមិនបានទទួលនូវការគាំទ្រពីស្វាមី និងគ្រួសារដើម្បីឈរឈ្មោះយកតំណែងនានាឡើយ ។ ពួកគេខ្វះខាតការគាំទ្រពី សហគមន៍ទូទៅនិងពីស្ត្រីខ្លួនឯងផ្ទាល់ ។

ដោយស្ត្រីមានការងារចម្បងដែលជាការងារមេផ្ទះ និងជាម្តាយ ស្ត្រីមានពេលនិងថាមពលតិចតួចដើម្បីចូល ខ្លួនទៅក្នុងវិស័យនយោបាយ ។ ដោយពួកគេជាប់រវល់នឹងការងារផ្ទះសម្បែង ចិញ្ចឹមកូនៗ និងថែរក្សាគ្រួសារកុំអោយបែក បាក់ ។ ជាការពិតណាស់ ភាគច្រើនពួកគេមានការមមាញឹក ជាមួយបញ្ហាចិញ្ចឹមជីវិត និងត្រូវតែលះបង់ខ្លួនឯង ដើម្បីរកប្រាក់ចំណូល ។

លើសពីនេះទៅទៀតឈរឈ្មោះ ដើម្បីការងារមុខតំណែង ត្រូវការទឹកប្រាក់ច្រើន ។ ដើម្បីមានឈ្មោះនៅក្នុង បញ្ជីគណបក្សនយោបាយ ស្ត្រីត្រូវតែធ្វើវិភាគទានជូនគណបក្ស ហើយទំហំនៃវិភាគទានទាំងនោះ ជាការកំណត់ឋានន្តរស័ក្តិ របស់ពួកគេ ។ ប៉ុន្តែមិនដូចបុរសទេ ស្ត្រីនឹងមិនលកគ្រឿងអាភរណ៍របស់ខ្លួនងាយៗ ដើម្បីប្តូរយកតំណែងនោះឡើយ ។ ស្ត្រីទុកលទ្ធភាពនេះ សំរាប់ស្វាមីរបស់ពួកគេ ប៉ុន្តែមិនសំរាប់ខ្លួនឯងឡើយ ។ ស្ត្រីមិនដូចបុរសទេ គេមិនដែលមើល ឃើញថា ការទទួលមុខតំណែង ជារបៀបមួយត្រឹមត្រូវក្នុងការបង្កើតប្រាក់ចំណូលនោះឡើយ ។

ស្ត្រីពុំមានបទពិសោធន៍ក្នុងប្រព័ន្ធនយោបាយទេ ។ ពួកគេពុំបានដឹងអំពីយន្តការ និងបណ្តាញនៅក្នុងប្រព័ន្ធបោះ ឆ្នោតជាតិនិងតាមតំបន់ ។ នៅក្នុងបទសម្ភាសន៍ផ្ទាល់មួយជាមួយបេក្ខនារីម្នាក់គាត់បាននិយាយថា គាត់បានទាមទារ ឈរឈ្មោះ លំដាប់ថ្នាក់លេខ២នៅក្នុងបញ្ជីបេក្ខជន ដោយសារគាត់បានរៀនសូត្រពីអង្គការចំរើនស្ត្រី ។ អង្គការចំរើនស្ត្រី បណ្តុះបណ្តាល បេក្ខជន ដែលជាស្ត្រីមកពីគ្រប់គណបក្សនយោបាយអំពីប្រព័ន្ធ នយោបាយក្នុងប្រទេស កម្ពុជា ។

យើងចាប់អារម្មណ៍យ៉ាងខ្លាំងទៅលើស្ត្រី ដែលមានភ័ព្វព្រេងវាសនាត្រូវបានជាប់ឆ្នោតឱ្យកាន់តំណែងដោយគេ នៅតែមិនទាន់បានរួមជាកម្លាំងមួយដើម្បីផ្លាស់ប្តូរគោលនយោបាយជាតិ និងច្បាប់ដើម្បីជួយស្ត្រីឯទៀតៗនៅឡើយ ។ ពួកគេត្រូវ តែរួបរួមគ្នា រៀបចំនិងអនុម័តរបៀបវារៈដើម្បីគាំទ្រស្ត្រីកម្ពុជាបើគេចង់ឃើញការប្រែប្រួលឡើងនោះ ។

## ប្រព័ន្ធនយោបាយប្រទេសកម្ពុជា

អង្គនីតិប្បញ្ញត្តិ និងរាជរដ្ឋាភិបាលកម្ពុជា នៅតែពុំទាន់យល់នូវគំនិត ក្នុងការកែតម្រូវការរើសអើង យែនឌ័រ នៅក្នុងអភិបាលកិច្ច ។ គេពុំទាន់ធ្វើសកម្មភាពសមស្របណាមួយ ដើម្បីផ្តល់ឱកាសច្រើនឱ្យបេក្ខនារីនៅឡើយទេ ។

បុរសចាប់តាំងពីកំរិតថ្នាក់ជាតិ រហូតដល់កំរិតមូលដ្ឋានត្រួតត្រាកាន់ក្តាប់យន្តការរបស់គណបក្សនយោបាយ ។ ក្នុងឆ្នាំ ១៩៩៨ នៅពេលដែលសង្គមស៊ីវិល ទាមទារឱ្យមាន កូតាចំនួន៣០ភាគរយ ផ្តល់ឱ្យទៅស្ត្រី បុរសភាគច្រើនដែល កំពុងកាន់អំណាច បានបដិសេធន៍ ដោយបញ្ជាក់ថាវិធានការនេះគឺជា ការលំអៀងទៅបុរស ។ ទោះបីជាយ៉ាងណាក៏ដោយ អ្នកនយោបាយបុរសទាំងនោះបាន ធ្វើទៅក្នុងតាមគោលជំហររបស់គណបក្សរបស់ពួកគេរៀងខ្លួនដែលកំនត់បេក្ខនារីរបស់ គេចំនួន ៣០ % ។ តែលទ្ធផលជាក់ស្តែងគេពុំបានទទួលលទ្ធផលតាមការគ្រោងទុកនោះទេ ។

ក្នុងដំណើការការជ្រើសរើសបេក្ខជនឈរឈ្មោះ កិច្ចសន្យាទាំងប៉ុន្មានត្រូវបានគេបំភ្លេចអស់ ។ ជាលទ្ធផល បុរសភាគច្រើនត្រូវបានដាក់បញ្ចូលក្នុងបញ្ជីគណបក្ស នៅក្នុងលំដាប់ខ្ពស់ បំផុតសំរាប់ការបោះឆ្នោត។

បន្ថែមទៅលើនោះទៀតស្ត្រីពុំត្រូវគេផ្តល់ឱ្យនូវឱកាស ឱ្យចូលរួមក្នុងក្រុមសំរេចចិត្តនៅក្នុងគណបក្សនយោបាយនៅឡើយទេ។ ស្ត្រីគ្រាន់តែគេរាប់ជានិមិត្តរូបតែប៉ុណ្ណោះ។

យុទ្ធនាការឃោសនារកសំលេងឆ្នោត ត្រូវការទឹកប្រាក់ដ៏ច្រើនពីបេក្ខជននានា។ គេពុំឃើញមានប្រព័ន្ធរដ្ឋការដើម្បីជួយកាត់បន្ថយការចំណាយក្នុងយុទ្ធនាការនយោបាយនេះឡើយ។ ចំពោះការបោះឆ្នោត៣លើកកន្លងទៅនេះរាប់ចាប់ពីឆ្នាំ ១៩៩៣ គ្រប់គណបក្សនយោបាយចំណាយថវិកាយ៉ាងច្រើនដើម្បីរៀបចំយុទ្ធនាការរបស់ពួកគេ ។

ប្រព័ន្ធគណបក្សពុំបើកចំហ និងពុំមានតម្លាភាពទៅនឹងការគ្រប់គ្រង និងការតែងតាំងបេក្ខជនឡើយ ។ នេះជាការបញ្ជាក់យ៉ាងច្បាស់ថា ដើម្បីអាចមានឈ្មោះក្នុងបញ្ជីបេក្ខជនលើគេ បេក្ខជនត្រូវបង់ប្រាក់ ឱ្យអ្នកកាន់បញ្ជីគណបក្ស។ ចង់បានឋានៈខ្ពស់ត្រូវហ៊ានចំណាយខ្ពស់ ។ ក្នុងករណីភាគច្រើនការបង់ប្រាក់គឺជាការបន្ថែមលើប្រាក់ប្រើសំរាប់យុទ្ធនាការសំខាន់ៗ និងការវិភាគទានសំរាប់យុទ្ធនាការជាតិ។

ប្រព័ន្ធបោះឆ្នោតកម្ពុជាគឺជាប្រព័ន្ធសមាមាត្រ។ គណបក្សនយោបាយបង្ហាញពីបញ្ជីបេក្ខជនទៅឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សំរាប់ការចុះឈ្មោះជាផ្លូវការ។ ចំនួនបេក្ខជនដែលគេបោះឆ្នោតឱ្យ គឺជាសមាមាត្រទៅនឹងសន្លឹកបោះឆ្នោតដែលទទួលបានដោយគណបក្សនីមួយៗ ។ បេក្ខជនដែលលើសពីការកំណត់ចំនួនឈ្មោះ គេដាក់ទៅក្នុងបញ្ជីឈ្មោះបំរុង សំរាប់អណត្តិ៥ឆ្នាំនៃមុខតំណែងនោះ។ ក្នុងអាណត្តិការងាររដ្ឋាភិបាល គណបក្សបានប្រើទំលាប់ដកមន្ត្រីគណបក្សដែលជាប់ឆ្នោត ពីសមាជិកភាពនៃគណបក្ស ហើយនៅពេលការផ្លាស់ប្តូរនេះ កៅអីមន្ត្រីនៅក្នុងសភាជាតិក៏បានគេដកហើយប្រគល់ទៅឱ្យអ្នកដែលមានឈ្មោះបន្ទាប់។

**តារាងទី២: ក្រុមប្រឹក្សាភិបាលៈ លទ្ធផលការបោះឆ្នោតអភិបាលកិច្ចក្នុងតំបន់**

| **តួនាទី** | **ស្ត្រី** | **ភាគរយ** | **បុរស** | **សរុប** |
|---|---|---|---|---|
| បេក្ខជន | ១២,៣៧៥ | **១៦.៤៣%** | ៦២,៩១២ | ៧៥,២៨៧ |
| មន្ត្រីជាប់ឆ្នោត | ៩៧៧ | **៩%** | ១០,៣០៦ | ១១,២៦០ |
| ប្រធានក្រុមប្រឹក្សាឃុំសង្កាត់ | ៣៤ | **២.០៩%** | ១,៥៨៧ | ១,៦២១ |
| ជំទុកទី១ | ៥៤ | **៣.៣៣%** | ១,៥៦៧ | ១,៦២១ |
| ជំទុកទី២ | ៧៨ | **៥%** | ១,៥៤៣ | ១,៦២១ |
| សមាជិកក្រុមប្រឹក្សា | ៨១១ | **១៣%** | ៥,៥៨៧ | ៦,៣៩៨ |

***ប្រភពៈ ក្រសួងមហាផ្ទៃ***

នៅក្នុង ១.៦២១ ឃុំសង្កាត់ ក្រសួងមហាផ្ទៃ បានជ្រើសរើស និងតែងតាំង ស្មៀន ស្ត្រីចំនួន ១៨៤ នាក់ ។

**បញ្ហា និង ឧបសគ្គ ចំពោះមន្ត្រីជាប់ឆ្នោតថ្នាក់មូលដ្ឋាន**

ប្រាក់ខែ ឬ ប្រាក់ឧបត្ថម្ភរបស់សមាជិកក្រុមប្រឹក្សាឃុំសង្កាត់មិនអាចចិញ្ចឹមជីវិតបានទេ ។ ជាលទ្ធផល ស្ត្រីដែលទទួលសម្ពាធពីសមាជិកគ្រួសាររបស់ខ្លួនដើម្បីរកប្រាក់ចំណូល បានសម្រេចចិត្តចាកចេញពីការងារនយោបាយមកធ្វើជាម្តាយ និងភរិយាដូចទម្លាប់ពីមុន។

ដោយសារតែគ្រួសារពឹងផ្អែកលើពួកគេយ៉ាងខ្លាំង ស្ត្រីភាគច្រើនមិនអាចធ្វើជាអ្នកស្ម័គ្រចិត្តក្នុងការងារនយោបាយឡើយ។

ជាមួយនឹងការយល់ឃើញជាធម្មតានៃសកម្មភាពនយោបាយ ដែលមានភាពហឹង្សា និងភាពឃោរឃៅស្ត្រីត្រូវបានគេរាប់ថាជាបញ្ហាសន្តិសុខ នៅក្នុងឃុំសង្កាត់របស់ពួកគេ ។ ទោះបីជាយ៉ាងណាក៏ដោយ ក្នុងបទសម្ភាសន៍ជាមួយសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ មន្ត្រីមេឃុំ សង្កាត់បាននិយាយថា ស្ត្រីមិនត្រឹមតែមិនបរាជ័យក្នុងកិច្ចការងាររបស់ពួកគេទេគេ ថែមទាំងមិនបានជួបប្រទះ នូវបញ្ហាសន្តិសុខ ក្នុងការអនុវត្តការងារទៀតផង។ ពីព្រោះតែការទាមទារពីតួនាទីរបស់ស្ត្រី នៅក្នុងសហគមន៍ គេតែងជឿថា ស្ត្រីខ្លួនឯងនឹងមិនបោះឆ្នោតឱ្យបេក្ខនារីជា ស្ត្រីដូចគ្នានោះទេ ។ ទោះជាយ៉ាងណាក៏ដោយ លទ្ធផលនៃការបោះឆ្នោត បង្ហាញថា ឃុំ-សង្កាត់មិនរើសអើងចំពោះបេក្ខនារីដូចដែលគេស្មានជាទូទៅនោះទេ ។ ដូច្នោះការរើសអើងគឺនៅលើអ្នកចាត់តាំងលំដាប់ថ្នាក់នៃបញ្ជីឈ្មោះនោះ ក្នុងចំណោមបេក្ខជន ១៦.៤៣% ឈ្មោះបោះឆ្នោតឃុំសង្កាត់ ៩% ដែលជាប់ឆ្នោតគឺជាស្ត្រី។ ក៏ប៉ុន្តែនៅពេលឡើងកាន់ តំណែងនៅក្នុងក្រុមប្រឹក្សាឃុំ-សង្កាត់ ឧទាហរណ៍ដូចជា ប្រធានឬ អនុប្រធាន ស្ត្រីដែលទទួល បានការដំឡើងតួនាទីមានតែ ២ភាគរយ ទៅ ៥ ភាគរយនៃអ្នកដែលជាប់ឆ្នោត តែប៉ុណ្ណោះ ។

នេះហាក់ដូចជា ស្ត្រីពុំត្រូវបានគេធ្វើការពិចារណាដោយអនុគ្រោះ ដោយគណបក្សរបស់គេឡើយ ដូច្នេះហើយពួកគេពុំត្រូវបានដាក់ក្នុងចំណាត់ថ្នាក់ទាប ។ ឧបសគ្គរបស់ស្ត្រីក្នុងការចូលរួមការបោះឆ្នោតកើតឡើងដោយសារតែពួកគេខ្វះខាតបទពិសោធន៍ នៅក្នុងប្រព័ន្ធនយោបាយ ប្រព័ន្ធនៃការតែងតាំង នៅក្នុងគណបក្ស និងដំណើរការជ្រើសរើសមន្ត្រីបន្ទាប់ពីការបោះឆ្នោត។

នៅក្នុងការគ្រប់គ្រងមូលដ្ឋានស្ត្រីមកពីគណបក្សផ្សេងៗអាចមានការសហការគ្នាប្រសើរដើម្បីបំរើដល់ម្ចាស់ឆ្នោតគេ ប៉ុន្តែលុះត្រាតែគេមាន អ្នកដឹកនាំឃុំ សង្កាត់ជួយសំរបសំរួលការទំនាក់ទំនង ល្អដោយមិនប្រកាន់គណបក្សនយោបាយ ។

ជំនាញក្នុងការគ្រប់គ្រងរបស់ប្រធានក្រុមប្រឹក្សាឃុំសង្កាត់ មានការទន់ខ្សោយ និងជួនកាល បណ្តាលអោយទំនាស់រវាងសមាជិក ក្រុមប្រឹក្សា ដែលមកពីគណបក្សនយោបាយផ្សេងៗគ្នា ។ មន្ត្រីឃុំ-សង្កាត់ នៅតែទទួល យកការណែនាំពីចៅហ្វាយស្រុក និងតាមខ្សែបន្ទាត់គណបក្ស ។

មេឃុំសង្កាត់នៅតែកាន់ក្តាប់សិទ្ធិក្នុងការសំរេចចិត្តភាគច្រើននៅឡើយ ។ ពួកគេក៏មានអំណាចលើការងារហិរញ្ញវត្ថុផងដែរ ប៉ុន្តែទោះបីជាស្ត្រីក្នុងក្រុមប្រឹក្សាឃុំ ក៏មិនសប្បាយនឹងករណីនេះដែរ ក៏ព្រោះពួកគេពុំដឹងថា ត្រូវធ្វើអន្តរាគមន៍យ៉ាងដូចម្តេចជាមួយ នឹងមន្ត្រីជាន់ខ្ពស់គេ។ អ្នកដឹកនាំឃុំមួយរូបបានរអ៊ូរទាំថា ភាគច្រើននៃពន្ធក្នុងតំបន់ដែលប្រមូលបាន ឬប្រាក់ចំណូលដែលរកបាន ក្នុងតំបន់ត្រូវបានយកដោយអភិបាលស្រុក និងអភិបាលខេត្ត ហើយនៅតែគេមិនអាចធ្វើអន្តរាគមន៍បាន ។

មេឃុំ ទទួលស្គាល់ថាគេបានជោគជ័យច្រើននៅពេលគេផ្ទេរសិទ្ធិអំណាច ឱ្យទៅក្រុមប្រឹក្សាដែលជាស្ត្រី។ ស្ត្រីទទួលបានជោគជ័យជាពិសេស ក្នុងការប្រមូលវិភាគទានផ្សេងៗ សំរាប់បំរើគំរោងអភិវឌ្ឍន៏ក្នុងភូមិ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ភាគច្រើននៃបុរស នៅក្នុងក្រុមប្រឹក្សា នៅតែបន្តគ្រប់គ្រងផ្នែកហិរញ្ញវត្ថុ នៅឡើយ ។

សមាជិកក្រុមប្រឹក្សាឃុំជាស្ត្រីមានអារម្មណ៏ថា សមាជិកដទៃ មិនទទួលស្វាគមន៏ពួកគេ ដោយចិត្តស្មោះនោះទេ នៅពេលប្រជុំក្រុមប្រឹក្សាឃុំ ។ តម្រូវការ និងបញ្ហារបស់ស្ត្រីក្នុងមូលដ្ឋានដែលគាត់លើកឡើងនៅមិនត្រូវបានគេដោះស្រាយបានពេញលេញនៅឡើយទេ។

**អង្គតុលាការ**

**តារាងទី៣: ការតែងតាំងស្ត្រីនៅក្នុងផ្នែកតុលាការ**

| | **តួនាទី និង ការតែងតាំង ឬជ្រើសរើស** | **ស្ថានភាពរបស់ស្ត្រី** |
|---|---|---|
| **ឧត្តមក្រុមប្រឹក្សានៃអង្គ ចៅក្រម** | ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវបានបង្កើតឡើង នៅឆ្នាំ ១៩៩៤ ដើម្បីឱ្យស្របទៅតាមច្បាប់នៅកម្ពុជា និងធ្វើឱ្យស្របទៅតាមរដ្ឋធម្មនុញ្ញ ។ មុខងាររបស់ក្រុមប្រឹក្សាគឺដើម្បីរក្សា ឱ្យបាននូវយុត្តិធម៌ និងឯករាជ្យភាព ដើម្បីរៀបចំបទបញ្ជាផ្ទៃក្នុងចៅក្រម ឱ្យស្របច្បាប់ និងរដ្ឋធម្មនុញ្ញ។ ទោះជាយ៉ាងណាក៏ដោយ ក្រុមប្រឹក្សាត្រូវបានអសកម្មចាប់តាំងពីការកកើតមក និងមានតួនាទីតិចតួចបំផុតនៅក្នុងទសវត្សរ៏កន្លងទៅនេះ ។ សមាជិកនៅក្នុងក្រុមប្រឹក្សានៃអង្គចៅក្រមនេះមកពីតុលាការកម្ពុជា ហើយតែងតាំងដោយ រាជរដ្ឋាភិបាល មុនការបោះឆ្នោតឆ្នាំ១៩៩៣ ។ | ស្ត្រីម្នាក់ត្រូវបានតែងតាំងឱ្យមានឋានៈខ្ពស់បំផុតនៅក្នុង គណៈតុលាការនេះ ដែលមានសមាជិកទាំងអស់ប្រាំបួនរូប ដែលក្នុងនោះ មានព្រះមហាក្សត្រជា ព្រះប្រធាន ។ |
| **សាលាឧទ្ធរណ៏** | មានតែសាលាឧទ្ធរណ៏មួយគត់នៅប្រទេសកម្ពុជា ដែលស្ថិតនៅក្នុងទីក្រុងភ្នំពេញ ។ មន្ត្រីគន្លឹះរបស់រដ្ឋាភិបាលជាអ្នកតែងតាំង សមាជិកនៃសាលាឧទ្ធរណ៏ ។ | មានសមាជិកជាស្ត្រីចំនួនពីររូបក្នុងចំណោមសមាជិក ១៩ នាក់។ |
| **ចៅក្រម** | មានស្ត្រីតិចតួចណាស់ ដែលតំណាងក្នុងប្រព័ន្ធតុលាការ ។ មាន ការខិតខំប្រឹងប្រែងយ៉ាងច្រើន ដើម្បីជ្រើសរើស និងបណ្តុះបណ្តាលស្ត្រីឱ្យក្លាយជាចៅក្រម និងព្រះរាជអាជ្ញា។ | ក្នុងចំណោមចៅក្រម ១៩៨ រូប ទូទាំង ប្រទេស មាន១៤រូប ជាស្ត្រី ។ លើសពីនេះស្ត្រី៦រូបក្នុង ចំណោមចៅក្រម៥០រូប បច្ចុប្បន្នកំពុងត្រូវតែបណ្តុះបណ្តាល នៅសាលាភូមិន្ទវិក្រឹត្រការចៅក្រម ។ |

| | | |
|---|---|---|
| **ព្រះរាជអាជ្ញា** | របៀបនៃការជ្រើសរើស ដូចបង្ហាញខាងលើ | ត្រឹមតែ ១,២ ភាគរយ ប៉ុណ្ណោះ នៃព្រះរាជអាជ្ញា គឺជាស្ត្រី ។ |
| **ក្រឡាបញ្ជី** | របៀបនៃការជ្រើសរើ ដូចបង្ហាញខាងលើ | ត្រឹមតែ ១៦,២ ភាគរយនៃ ក្រឡាបញ្ជី ដែលបានតែងតាំងជាស្ត្រី ។ |
| **គណៈមេធាវី** | មិនសូវមានមេធាវីជាស្ត្រី ច្រើនដែលកំពុងអនុវត្ត ឬបានបញ្ចប់ការសិក្សា នៅប្រទេសកម្ពុជា ។ ស្ថានភាពនេះឆ្លុះបញ្ចាំងនៅ ចំនួនតួរលេខទាបនៃមេធាវី ជាស្ត្រីនៅក្នុងគណៈមេធាវី ។ | ក្នុងចំណោមតួរលេខសរុបនៃមេធាវី កំពុងអនុវត្តក្នុង ប្រទេស កម្ពុជា ១០,៥ ភាគរយ គឺជា ស្ត្រី និង ៨៩,៥ ភាគរយជា បុរស ។ |

*ប្រភព: រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា*

**រូបទី២: ស្ត្រីនៅក្នុងប្រព័ន្ធតុលាការ**




*ប្រភព: ក្រសួងមហាផ្ទៃ*

## បញ្ហា និងឧបសគ្គ

ក្នុងរយៈពេលពីរទសវត្សរ៍ បន្ទាប់ពីសង្គ្រាមស៊ីវិល រដ្ឋាភិបាលកម្ពុជាបានជ្រើសរើស មនុស្សសំខាន់ ក្នុងជួរកងទ័ពមកបណ្តុះបណ្តាលបង្ហាត់ឱ្យកាន់តួនាទីផ្សេងៗ នៅក្នុងប្រព័ន្ធតុលាការ ។ ស្ត្រីមិនសូវដែលបាន ឃើញមានកាន់តួនាទីខ្ពស់នៅក្នុងគណបក្សនយោបាយពីឆ្នាំ ១៩៧៩-១៩៩១ ។

គេមើលឃើញថាប្រព័ន្ធតុលាការកម្ពុជាមិនមានដំណើរការល្អ និងអាចផ្តល់យុត្តិធម៌ ឱ្យទៅប្រជាជនឡើយ ។ ម៉្យាងវិញទៀត ប្រព័ន្ធនេះ គឺពុករលួយ និងលំអៀងលើអ្នកមានលុយ និងអំណាច ។ មនុស្សភាគច្រើនជៀសវាងការឡើង

តុលាការ ហើយសុខចិត្តទៅដោះស្រាយបញ្ហា នៅក្រៅប្រព័ន្ធតុលាការជាង ។

ប្រព័ន្ធតុលាការច្រើនតែធ្វើការដោះស្រាយក្តី ដែលទាក់ទងទៅនឹងករណីឧក្រិដ្ឋកម្ម ហើយមិនសូវ មានកាត់ក្តីក្តាំ ទាក់ទងទៅនឹងបញ្ហាសង្គមទេ ។ ហេតុនេះស្ត្រីមិនចាប់អារម្មណ៍ធ្វើការងារនេះទេ ដោយគេយល់ឃើញថាការងារនេះពាក់ព័ន្ធរឿងឧក្រិដ្ឋកម្មដែលជារឿងរបស់បុរស ។ បុរសធ្វើការសំរេចចិត្តទាំងអស់លើការតែងតាំង និងស្ត្រីមិនមានតួនាទីនៅក្នុងការ សម្រេចចិត្តឡើយ ។

## អន្តនីតិប្រតិបត្តិ

មានការរីកចំរើន ក្នុងរយៈពេល១០ឆ្នាំកន្លងមក ពី ១៩៩៣ ដល់ ២០០៣ ដោយគេឃើញមានស្ត្រីកាន់តំណែងខ្ពស់ខ្លះ ក្នុងជួររដ្ឋាភិបាល ។

ក្នុង ឆ្នាំ ១៩៩៨ ស្ត្រី២រូបកាន់តួនាទីជារដ្ឋមន្ត្រី ក្នុងក្រសួងកិច្ចការនារី និងអតីតយុទ្ធជន និងក្រសួង វប្បធម៌ និងសិល្បៈ ។ នេះគឺជាការរីកចំរើនមួយ ពីព្រោះក្នុងឆ្នាំ ១៩៩៣ ពុំមានស្ត្រីឡើយ ។

ក្នុងឆ្នាំ១៩៩៨ ស្ត្រី៣រូបត្រូវបានតែងតាំងមុខតំណែងមួយក្នុងក្រសួងសង្គមកិច្ច បណ្តុះបណ្តាលវិជ្ជាជីវៈនិង ២ នៅក្រសួងកិច្ចការនារី ។ ក្នុងឆ្នាំ ១៩៩៣ ពុំមានស្ត្រីឡើយ ។ ទាំងក្នុងឆ្នាំ ១៩៩៣ និង ឆ្នាំ១៩៩៨ ស្ត្រី៥រូបបានកាន់មុខតំណែងជាអនុរដ្ឋ-លេខាធិការ ។ ប៉ុន្តែ ពុំទាន់មានអិបាលខេត្ត និងអភិបាលក្រុងជាស្ត្រីនៅឡើយទេ ។ មានតែស្ត្រីមួយរូប ប៉ុណ្ណោះ ដែលត្រូវមានងារជា អភិបាលរងទីមួយខេត្ត នៅឆ្នាំ ១៩៩៣ និង មានតែមួយរូបជាអភិបាលរងទីពីរ នៅឆ្នាំ ១៩៩៨ ។

**តារាងទី៤: ស្ត្រីដែលមានតួនាទីសំខាន់ៗនៅក្នុងតួនាទីរដ្ឋាភិបាល**

| តួនាទី | ១៩៩៣ | | ១៩៩៨ | |
|---|---|---|---|---|
| | បុរស | ស្ត្រី | បុរស | ស្ត្រី |
| **រដ្ឋមន្ត្រី** | ១00% | 0% | ៩២.៦0% | ៧.៤0% |
| **រដ្ឋលេខាធិការ** | ១00% | 0% | ៩៤% | ៦% |
| **អនុរដ្ឋលេខាធិការ** | ៩៦% | ៤% | ៩៦% | ៤% |
| **អភិបាលខេត្ត-ក្រុង** | ១00% | 0% | ១00% | 0% |
| **អភិបាលរងទី១** | ៩៨.៥៨% | ១.៤២% | ១00% | 0% |
| **អភិបាលរងទី២** | ១00% | 0% | ៩៨.៥៨% | ១.៤២% |
| **អភិបាលស្រុក-ខ័ណ្ឌ** | ១00% | 0% | ១00% | 0% |
| **អភិបាលរងស្រុក-ខ័ណ្ឌ** | ៩៩.៦% | 0.៣៦% | ៩៩% | 0.៩% |

***ប្រភព: ក្រសួងមហាផ្ទៃ***

យើងសង្កេតថាពុំមានការរីកចំរើន ជាតួលេខនៃចំនួនស្ត្រីដែលកាន់តំណែងជាអភិបាល នៅឯក៏រិតស្រុក និងខេត្ត ឡើយ ។ ទោះជា យ៉ាងណាក៏ដោយ ក៏មានការរីចំរើនតិចតួចក្នុងតួលេខ នៃអភិបាលស្រុករងដែលនៅក្នុង ៥៥១ ស្រុក និងខ័ណ្ឌ ទូទាំងប្រទេស មានពីស្ត្រី២រូប ទៅ ៥រូបកាន់តំណែងជាអភិបាលស្រុករង ពីឆ្នាំ ១៩៩៣ ដល់ ឆ្នាំ១៩៩៨ ។

**គណៈកម្មាធិការបោះឆ្នោត**

មានការរីកចំរើននៅក្នុងចំនួននៃស្ត្រី ដែលមានតួនាទីសំខាន់នៅក្នុងយន្តការនយោបាយ គឺគណៈកម្មាធិការបោះឆ្នោតជាតិ ។ នៅក្នុងឆ្នាំ ១៩៩៨ គ្មានស្ត្រីម្នាក់ជាសមាជិក នៅក្នុង គណៈកម្មាធិការបោះឆ្នោត ជាតិឡើយ ក្នុងចំណោមសមាជិកចំនួន ១១នាក់ ។ ប៉ុន្តែនៅក្នុងឆ្នាំ២០០៣ មានស្ត្រី ២នាក់ដែលត្រូវគេតែងតាំង នៅក្នុងគណៈកម្មាធិការបោះឆ្នោតជាតិ ដែលមានសមាជិក៥នាក់ ។ មានសមាជិកស្ត្រី ២រូប ដែលមានឥទ្ធិពល នៅលើការរៀបចំស្ថាប័នប្រមូលទិន្នន័យ សំរាប់ដំណើរការបោះឆ្នោត ។

**អត្រាស្ត្រីក្នុងចំណោមមន្ត្រីសាធារណៈ គ្រប់ក៏រិត បុគ្គលិករដ្ឋបាល បច្ចេកទេស និងអ្នក គ្រប់គ្រង**

ដោយសារតែធនធាន និងពេលវេលាតិចតួច អ្នកស្រាវជ្រាវ ពុំមានលទ្ធភាព ធ្វើការប៉ាន់ស្មាន ចំនួនបុគ្គលិក រដ្ឋបាល បច្ចេកទេស និងបុគ្គលិកគ្រប់គ្រងនៅក្នុងក្រសួង ព្រោះនៅពេលដែលយើងចាប់ផ្តើម ធ្វើការនេះស្ថាបន័ទាំងឡាយ ពុំមានទិន្នន័យ ។ ក្រសួងរក្សាទុកតែចំនួនបុគ្គលិកស្ត្រី និងបុរស ប៉ុន្តែពុំមានរក្សាទុកទិន្នន័យទៅតាមផ្នែក និងក៏រិតនៃ តួនាទីបុគ្គលិកនីមួយៗទេ ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏ក្រសួងមួយចំនួយកំពុងមានវិធានការ ដើម្បីធ្វើឱ្យការប្រមូល ទិន្នន័យឱ្យមានភាព ប្រសើរឡើងទៅអនាគត។

**តារាងទី៥- ស្ត្រីនៅក្នុងសេវាកម្មសាធារណ**

| *តួនាទី* | *ភាគរយរបស់ស្ត្រី* | *ភាគរយរបស់បុរស* | *សរុប* | *សរុបភាគរយ* |
|---|---|---|---|---|
| **ក្រ.សុខាភិបាល** | ២៣.៥០% | ៧៦.៥០% | ៣៧៧២ | ១០០% |
| **ក្រ.អប់រំយុវជន និងកីឡា** | ៣១.៣០% | ៦៨.៧០% | ៣១០១ | ១០០% |
| **ក្រ.កសិកម្ម** | | | ១០០% | ១០០% |
| **ក្រ.ព័តិមាន និងឃោសនាការ** | ២៩.៥០% | ៧០.៥០% | ១២៩៦ | ១០០% |
| **ក្រ.សាធារណការនិងដឹកជញ្ជូន** | ៣១% | ៦៩% | ៤៩១ | ១០០% |
| **ក្រ.ប្រៃនីយ៍និងទូរគមនាគមន៍** | ៣៦.៣០% | ៦៣.៧០% | ១៣៦០ | ១០០% |
| **ក្រ.សួងកិច្ចការនារី និងអតីត យុទ្ធជន** | ៦៩% | ៣១% | ២១៦ | ១០០% |
| **ក្រ.វប្បធម៏ និងវិចិត្រសិល្បះ** | ៣៥.៤០% | ៦៤.៦០% | ១៦២៥ | ១០០% |
| **ក្រ.ការបរទេស និង សហប្រតិបត្តិការអន្តរជាតិ** | ៣៦.៣០% | ៦៣.៧០% | ៤៥៧ | ១០០% |
| **ក្រ.យុត្តិធមិ** | ១៤.៤០ | ៨៥.៦០% | ១១៨៧ | ១០០% |

***ប្រភពៈ ក្រសួងមហាផ្ទៃ***

**បញ្ហាដែលស្ត្រីជួបប្រទះ នៅក្នុងផ្នែកសេវាកម្មសាធារណ**

១-ធ្វើការងារក្រៅផ្ទះ ជាពិសេស នៅក្នុងផ្នែកសាធារណៈ គឺត្រូវបានគេគិតថា ជាការងារបុរស [2]

២-ប្រជាជនជាទូទៅជឿជាក់ថា បុរសមានការសំរេចចិត្តលឿន និងមានប្រសិទ្ធភាពជាងស្ត្រី

៣-មានតែបុរស ០,០៩ % ទេ ដែលពេញចិត្តធ្វើការនៅក្រោមស្ត្រី, តែមាន ៥០ % ពេញចិត្តធ្វើការតែក្រោមបុរស ហើយសល់ពីនេះ គេផ្អែកទៅលើគុណសម្បត្តិ និងបុគ្គលិកលក្ខណៈរបស់ស្ត្រី ដោយពុំគិតអំពីយែនឌ័រទេ ។ ផ្ទុយទៅវិញ មានស្ត្រី ៦៧ % ដែលពេញចិត្តធ្វើការងារនៅក្រោមស្ត្រីគ្នាឯង ហើយមាន៣៤ % ពេញចិត្តធ្វើការងារនៅក្រោមបុរស ។

៤-ស្ត្រី ពុំបានទទួលប្រយោជន៍ ពីការដំឡើងតួនាទី ដែលជាទូទៅគេច្រើនតែធ្វើទៅតាមការចូលចិត្តផ្ទាល់ខ្លួន តាមខ្សែរយៈនយោបាយ និង អំពើពុករលួយ ។ បុរសចូលចិត្តចំណាយប្រាក់ ដើម្បីបានដំឡើងតួនាទីជាជាងការពឹងផ្អែកលើសមត្ថភាពរបស់ខ្លួន ។ ពួកគេមានបទពិសោធន៍ច្រើន នៅក្នុងគណបក្សនយោបាយហើយជាទូទៅគេជាអ្នកធ្វើការសម្រេចចិត្ត ទៅលើការដំឡើងតួនាទី ។

៥-ស្ត្រីដែលបំរើការនៅក្នុងសេវាសាធារណៈជួបប្រទេះការរើសអើងច្រើន ។ មានតែ៣១ភាគរយប៉ុណ្ណោះដែលជាមន្ត្រីស៊ីវិលស្ត្រី ។ ពុំមានទិន្នន័យបញ្ជាក់អំពីតំណែងស្ត្រី ដែលបំរើការនៅក្នុងសេវាសាធារណៈឡើយ ។ ប៉ុន្តែការប៉ាន់ប្រមាណព្រាល១ ទៅលើក្រសួងចំនួន ១០ បានបង្ហាញថា ស្ត្រីកាន់ តំណែង ជាអ្នកគ្រប់គ្រងមានតែ ៩.១ % ប៉ុណ្ណោះ ។ ចំនួនស្ត្រីដែលមានតួនាទីជាអ្នកគ្រប់គ្រង មានចំនួន២៥.៨ ដែលស្ថិតនៅក្នុងក្រសួងសុខាភិបាល ហើយ ០ % នៅក្នុងក្រសួងកិច្ចការសង្គម ។ គ្មានស្ត្រីណាដែលធ្វើជាអគ្គនាយកនៅបណ្តាក្រសួងទាំងនោះឡើយ ។ មានតែ១១ % ដែលជាអគ្គនាយករងនិងមាន ១០ % ជាប្រធាននាយកដ្ឋាន ឬជា ប្រធាន នាយកដ្ឋានរង ។ ស្ត្រីដែលស្ថិតនៅក្នុងក្រសួងទាំងនោះជឿជាក់ថា ពួកគេពុំទទួលបាននូវភាពយុត្តិធម៌ក្នុងការដំឡើង តួនាទី ឡើយ ។ ពួកគេមានអារម្មណ៍ថា អ្នកគ្រប់គ្រងរបស់ពួកគេ ពុំជឿលើសមត្ថភាពរបស់ពួកគេ ហើយថែមទាំងពុំផ្តល់ឱកាសឱ្យពួកគេទទួលបាននូវការបណ្តុះបណ្តាលទៀតផង ។

៦-ស្ត្រីដែលធ្វើការជារាជការស៊ីវិល មានការភ័យខ្លាចថា ពួកគេនឹងបាត់បង់ការងាររបស់គេ នៅពេលដែលកំណែទម្រង់រដ្ឋបាលស៊ីវិលត្រូវបានអនុវត្ត ។ ការពិគ្រោះយោបល់ បានឬញ្ជាក់ប្រាប់ថា បុរសដែលមានតួនាទីធ្វើការសម្រេចចិត្ត ពុំមានការយកចិត្តទុកដាក់ទៅលើបញ្ហាយែនឌ័រ ដើម្បីដំឡើងតួនាទី នោះឡើយ ។ ស្ត្រីពុំមានលក្ខណៈគ្រប់គ្រាន់ក្នុងការទទួលនូវកម្រៃបន្ថែមពីគោលការណ៍អត់ការងារធ្វើ របស់ប្តី ឬប្រពន្ធនោះឡើយ ។ ក្នុងចំណោមអ្នកបណ្តុះបណ្តាលចំនួន ១,៤៧០ នាក់ ដែលធ្វើការនៅក្នុងសាលាភូមិន្ទរដ្ឋបាល មាន ស្ត្រីតែ ៦ %ប៉ុណ្ណោះ ដែលបានទទួលការបណ្តុះបណ្តាល ។

[2] ស្ត្រី និងភាពដឹកនាំ-ដោយ បណ្ឌិត បូ ចំសឺន-ទំព័រទី៧៧

## ៣.២. ភាពជាអ្នកដឹកនាំរបស់ស្ត្រីនៅក្នុងអង្គការៈ

### ៣.២.១. ការប្រៀបធៀបចំណែករបស់ស្ត្រី និងបុរសនៅក្នុងភាពជាអ្នកដឹកនាំ នៅក្នុងអង្គការមិនមែនរដ្ឋាភិបាល ។

**រូបទី៣ៈ ការប្រៀបធៀបការរួមចំណែករបស់ស្ត្រី និងបុរសនៅក្នុង ភាពជាអ្នកដឹកនាំ នៅក្នុងអង្គការមិនមែនរដ្ឋាភិបាល ។**




*ប្រភពៈ ក្រសួងមហាផ្ទៃ*

ស្ត្រី កាន់តំណែងជាអ្នកគ្រប់គ្រង នៅក្នុងអង្គការមាន១៧ % និង ៩៩ % នៅក្នុងសហគមន៍ ។ នៅក្នុង សហគមន៍ ប្រធានត្រូវជ្រើសរើសដោយសមាជិក ។ ដូច្នេះ មានស្ត្រីតិចតួច ដែលត្រូវបាន គេបោះឆ្នោតឱ្យកាន់តំណែង បើប្រៀបធៀបទៅនឹងអ្នក ដែលមានគំនិតផ្តួចផ្តើម និងរៀបចំអង្គការ ឬត្រូវបានគេជ្រើសរើសឱ្យដឹកនាំក្នុងអង្គការ ។

**ឧបសគ្គដែលស្ត្រីប្រឈមមុខនឹងការដឹកនាំអង្គការ :**

១- អ្នកដឹកនាំជាស្ត្រីត្រូវបានគេវាយតំលៃថា មានភាពទន់ខ្សោយ នឹងត្រូវធ្វើការយ៉ាងខ្លាំងលើសគេ ដើម្បីបង្ហាញសមត្ថភាព ទៅលើបុគ្គលិកផ្សេងទៀត ។

២-ស្ត្រីត្រូវទទួលបន្ទុកត្រួតពីរ គឺធ្វើជាអ្នកដឹកនាំផង និងថែរក្សាគ្រួសាររបស់គេ ដែលមានស្វាមី និងកូនផង ។

៣-ស្ត្រីក៏ត្រូវស្ថិតនៅក្រោមសម្ពាធដ៏ច្រើន ក្នុងការបរិច្ចាគពេលវេលា និងប្រាក់កាស ដើម្បីកសាងវត្ត អារាម និងក្រុមផ្សេងទៀត ដូចជា ការងារសហគមន៍ និងពិធីផ្សេងៗទៀត ។

៤-ស្ត្រីដែលស្ថិតក្នុងមុខងារជាអ្នកដឹកនាំកំពូល មានអារម្មណ៍ថា ខ្លួនឯកោ ដោយគ្មានអ្នកគាំទ្រជួយដោះស្រាយបញ្ហាប្រចាំថ្ងៃ ។

៥-ស្ត្រីត្រូវបានគេដាក់សម្ពាធឱ្យរក្សាភាពទន់ភ្លន់ ។ ពួកគេត្រូវបានគេហៅថា " ឆ្នាស់ " ឯ បុរសវិញត្រូវបានគេគិតថា គាត់ជាអ្នកធ្វើការម៉ឺងម៉ាត់ ។

៦-ស្ត្រីដែលជាអ្នកដឹកនាំមានការលំបាក ក្នុងការចូលរួមក្នុងការងារសង្គមនៅពេលយប់ ទោះបីជាការងារនោះជាការងារក្នុងតួនាទីរបស់ខ្លួនក៏ដោយ ។

៧-ស្ត្រីដែលជាអ្នកដឹកនាំមានការលំបាក ក្នុងការបំពេញតួនាទីរបស់ខ្លួន នៅពេលដែលគេមានកូន ។ គេពុំមានការ

គាំពារសង្គមកិច្ចសំរាប់ក្មេងឡើយដែលបណ្តាលឱ្យ អង្គការដែលស្ត្រីធ្វើការនោះ ពុំអនុញ្ញាតឱ្យពួកគាត់ឈប់សំរាកមាតុភាពបានយូរឡើយ ។

### ៣.២.២. ប្រៀបធៀប ការរួមចំណែករបស់ស្ត្រី និងបុរសក្នុងភាពជាអ្នកដឹកនាំក្នុងសហជីពកម្មករ :

**រូបទី៤- ប្រៀបធៀបការរួមចំណែក របស់ស្ត្រី និងបុរសក្នុងភាពជាអ្នកដឹក ក្នុងសហជីពកម្មករ :**




***ប្រភព: អង្គការពលកម្មកម្ពុជា-មេសា ២០០៤***

អតុល្យភាព ចំនួនស្ត្រី និងបុរស ដែលជាអ្នកដឹកនាំ គឺមានភាពខុសគ្នាឆ្ងាយណាស់ នៅក្នុងសហជីពកម្មករ ។ មានតែស្ត្រី ២នាក់ ប៉ុណ្ណោះ ដែលជាអ្នកដឹកនាំ នៅក្នុងសហជីពកម្មករចំនួន ១៦ នៃកម្មកររោងចក្រ ដែលកម្មករជាង២០ម៉ឺននាក់ដែលសុទ្ធតែជានារី នៅក្នុងប្រទេសកម្ពុជា ។ ទោះបីជាគេទទួលស្គាល់ថា ស្ត្រីអាចដោះស្រាយបញ្ហាបានល្អជាងបុរសក៏ដោយ ក៏សហជីពកម្មករពុំបានលើក តម្កើងឱ្យស្ត្រីជាអ្នកដឹកនាំឡើយ ។ ហេតុផលមានដូចខាងក្រោម:

១-ស្ត្រីមិនបោះឆ្នោតឱ្យស្ត្រីគ្នាឯងទេ ។ ពួកគេមិនជឿជាក់ថា ស្ត្រីអាចកាន់កាប់តំណែង ជាអ្នកដឹក នាំនៅក្នុងសហជីពកម្មករ និងគ្មានកម្លាំងគ្រប់គ្រាន់ ដើម្បីប្រឈមមុខជាមួយអាជ្ញាធរ នៅក្នុងស្ថានភាពដូចជាការធ្វើកូដកម្មជាដើម ។

២-ស្ត្រីខ្លួនឯងចូលចិត្តផ្តល់តួនាទីជាអ្នកដឹកនាំទៅឱ្យបុរស ។ គេបោះបង់បេក្ខភាពឱ្យទៅបុរស នៅពេលមានការប្រកួតប្រជែងគ្នា ។

៣-បុរសមិនយកចិត្តទុកដាក់ឱ្យស្ត្រីធ្វើជាអ្នកដឹកនាំទេ ទោះបីជាស្ថិតនៅក្នុងស្ថានភាពកំពុងមានកូដកម្មយ៉ាងណាក៏ដោយ ប៉ុន្តែស្ត្រីត្រូវគេបញ្ជូនឱ្យទៅខាងក្រៅ ដើម្បីប្រឈមមុខនឹងអាជ្ញាធរ ។ គេទទួលស្គាល់ថា ស្ត្រីពូកែជាងបុរសក្នុងការធ្វើជាអ្នកសម្របសម្រួលជាមួយម្ចាស់ក្រុមហ៊ុនឬប៉ូលីស ដោយហេតុថា ប៉ូលីសមិនវាយធ្វើបាបទៅលើស្ត្រីឡើយ ។

៤- មនុស្សទាំងអស់ជឿជាក់ថា បុរសមានកម្លាំងពលំខ្លាំងជាងស្ត្រី ។ ការងារកាត់ដេរ មិនត្រូវបានគេគិតថា ជាការងារដែលត្រូវការកម្លាំងពលកម្មខ្លាំង ឬជាការងារធ្ងន់នោះឡើយ ។

៥-គេជឿជាក់ថា ស្ត្រីមានការយឺតយ៉ាវក្នុងការយកព័ត៌មាន ពិព្រោះថា ពួកគេមានកិច្ចការផ្ទះច្រើន និងមិនមានពេលវេលាគ្រប់គ្រាន់ ដើម្បីចេញទៅក្រៅ និងអាចធ្វើការទំនាក់ទំនងជាមួយអ្នកក្រៅបាន ។

៦-ស្ត្រីជឿជាក់ថា ពួកគេមិនបានទទួលការអប់រំគ្រប់គ្រាន់ ដើម្បីអាចក្លាយទៅជាអ្នកដឹកនាំសហជីពទេ ។

៧-គេស្មានថា ស្ត្រីមិនមានបទពិសោធន៍គ្រប់គ្រាន់ ក្នុងការគ្រប់គ្រង និងការងារធ្វើគោលនយោបាយទេ ។

## ៣.២.៣. ប្រៀបធៀបការរួមចំណែក របស់ស្ត្រីក្នុងភាពជាអ្នកដឹកនាំ ក្នុងស្ថាប័នអប់រំ ៖

**រូបទី ៩៖ ស្ត្រីដែលមានតួនាទីជាអ្នកដឹកនាំ នៅក្នុងនឹងស្ថាប័នអប់រំ**




***ប្រភព៖ ក្រសួងអប់រំយុវជន និងកីឡា ឆ្នាំ ២០០៤***

## <u>បញ្ហា និងឧបសគ្គ</u>

អំពើពុករលួយ គឺជាឧបសគ្គចម្បងក្នុងការតែងតាំងស្ត្រី ដើម្បីមានមុខតំណែង ធ្វើការសម្រេចចិត្តនៅក្នុងសេវាកម្មសាធារណៈ ។ អ្នកធ្វើការសម្រេចចិត្ត នៅក្នុងគណបក្សនយោបាយធំៗ ធ្វើការតែងតាំងភាគច្រើនតែបុគ្គលណាដែលបានបង់ប្រាក់ ដើម្បីទទួលយកមុខតំណែង។ សរុបឱ្យខ្លីទៅបុរស( ហើយពេលខ្លះមានស្ត្រី) ទិញមុខតំណែងគេ ។

ច្បាប់សេវាកម្មសាធារណៈមិនបានការពារស្ត្រីពីការរើសអើងឡើយ ។ ស្ត្រីត្រូវបានគេមើលរំលង ក្នុងការដំឡើងតួនាទី ទោះបីជា ស្ត្រីទាំងនោះមានជំនាញក្នុងផ្នែកនេះក៏ដោយ ។

ការខ្វះខាតនៃការគាំទ្រយ៉ាងសកម្មពីស្វាមី និងសហគមន៍ គឺជាបញ្ហាចម្បងផងដែរ ពិព្រោះថា ស្ត្រីត្រូវបានគេផ្ទុកការងារទាំងក្នុង និងខាងក្រៅយ៉ាងច្រើន ។ ស្ត្រីត្រូវបានគេគិតជាអាទិភាពក្នុង តួនាទីរបស់គាត់ដែលជាការងារផ្ទះសម្បែងនេះឯង ។

តំណែងខ្ពស់ត្រូវបានគេគិតថា ជាការងារនយោបាយ ដូច្នេះ វាហួសពីការចាប់អារម្មណ៍ របស់ស្ត្រី ។

ស្ត្រីមិនត្រូវបានគេលើកទឹកចិត្ត ដើម្បីស្វែងរកការសិក្សាកំរិតខ្ពស់ទេ ។ ក្មេងស្ត្រី ជាធម្មតា ត្រូវបានគេទុកឱ្យនៅតែផ្ទះ ដើម្បីជួយការងារផ្ទះតែប៉ុណ្ណោះ ។ នៅពេលដែលឪពុកម្តាយគ្មានលទ្ធភាពនឹងបញ្ជូនកូន ទៅសាលារៀន កូនស្រីត្រូវនៅផ្ទះ ។ ចំណែកកូនប្រុសគេ អាចទៅបន្តការសិក្សារបស់ពួកគេបាន ។ ប្រសិនបើក្មេងស្រីអាចទៅសាលារៀនបាន គេក៏ត្រូវទាមទារឱ្យ ផ្គត់ផ្គង់ដល់គ្រួសារ ដូចក្មេងប្រុសដែលទៅរៀនអ៊ីចឹងដែរ ។

**តារាងទី ៦: អត្រាក្មេងស្រីនៅក្នុងសាលា**

| | ស្ត្រី | ភាគរយ | បុរស | ភាគរយ | សរុប |
|---|---|---|---|---|---|
| **សិស្សដែលរៀនកំរិតទាបជាងមធ្យមសិក្សា** | | | | | |
| **កំរិតទាបជាមធ្យមសិក្សា** | ១៣៩,៩៣៧ | ៣៨.៦៥ | ២១៥,៦៩៨ | ៦១.៣៥ | ៣៥១,៦៥៣ |
| **កំរិតខ្ពស់ជាងមធ្យមសិក្សា** | ៣៦,៤១១ | ៣២.១ | ៧៦,៩៩៣ | ៦៧.៩០ | ១១៣,៤០៤ |
| **សិស្សដែលករៀននៅកំរិតអប់រំខ្ពស់** | | | | | |
| **សិស្សដែលទទួលអាហារូបករណ៍** | ២,៣០១ | ២៦ | ៦,៥៤៦ | ៧៤ | ៨,៨៤៧ |
| **បង់ថ្លៃឈ្នួល** | ៦,១៩៨ | ៣១.៤ | ១៣,៥៣៥ | ៦៨.៦ | ១៩,៧៣៣ |
| **សរុប** | ៨,៤៩៩ | ៣០ | ២០,០៨១ | ៧០.២៧ | ២៨,៥៨០ |

***ប្រភព: អង្គការចំរើនស្ត្រី***

មានក្មេងស្រី តិចជាងក្មេងប្រុស បើគិតនៅក្នុងកំរិតការអប់រំទាំងអស់ ដូចដែលបានបង្ហាញ នៅក្នុង តារាងទី៦ ។ នៅក្នុងកំរិតមធ្យមសិក្សា ក្មេងស្រីមានចំនួន ៣៩ % នៃចំនួនសរុបនៃក្មេង ដែលបានបោះបង់សាលា ។ ៧៤ % នៃសិស្សទាំងអស់ គឺជាជាក្មេងប្រុស ។ ចំណែក ២៦ % គឺជាក្មេងស្រី ។ ប្រព័ន្ធអប់រំគួរតែធ្វើការកែតម្រូវ អសមភាពនេះ ។ នេះជាការបញ្ជាក់ថា រដ្ឋាភិបាលមិនមានប្រព័ន្ធសមស្រប ដែលជួយគាំទ្រក្មេងស្រី ដែលមានបំណងចង់បន្តការសិក្សាកំរិតខ្ពស់ និងចង់រៀបចំខ្លួន ដើម្បីទទួលខុសត្រូវ ថែមទៀត ចំពោះគ្រួសារ និងសង្គម ។

**៣.២.៤.ប្រៀបធៀបការចូលរួមចំណែក របស់បុរស និងស្ត្រីក្នុងភាពជាអ្នកដឹកនាំរបស់ពួកគេក្នុង សាជីវកម្ម**

**រូបទី៦: ប្រៀបធៀបការចូលរួមចំណែករបស់បុរស និងស្ត្រីក្នុងភាពជាអ្នកដឹកនាំរបស់ ពួកគេក្នុងសាជីវកម្ម :**




***ប្រភព: CAID - ខែមេសា ឆ្នាំ២០០៤***

### ៣.២.៥. បែងចែកប្រៀបធៀបស្ត្រីក្នុងភាពជាអ្នកដឹកនាំនៅក្នុងអាជីវកម្មខ្នាតតូច :

**រូបទី៧: បែងចែកប្រៀបធៀបស្ត្រីក្នុងភាពជាអ្នកដឹកនាំនៅក្នុងអាជីវកម្មខ្នាតតូច :**




*ប្រភព: ការសិក្សាពីស្ថានភាពរបស់ស្រីក្មេងៗដែលកំពុងសិក្សា " ជំនាញមិនជាប្រពៃណីនៅក្នុង ប្រទេសកម្ពុជា " ដោយវែនឌ័រ និង ការអភិវឌ្ឍន៍កម្ពុជា-ភ្នំពេញ ឆ្នាំ ២០០២ ។*

## ៣.៣. ការចូលរួមរបស់ស្ត្រីនៅក្នុងគោលនយោបាយបោះឆ្នោត

### ៣.៣.១ សិទ្ធិស្របច្បាប់របស់ស្ត្រីក្នុងការបោះឆ្នោត

មាត្រាទី៧ នៃរដ្ឋធម្មនុញ្ញ ដែលធានានូវភាពស្មើភាពគ្នា ក្នុងការបោះឆ្នោត រវាងបុរស និងស្ត្រី។ ស្ត្រីត្រូវបានគេទទួលស្គាល់ឱ្យមានសិទ្ធិបោះឆ្នោត នៅក្នុងឆ្នាំ ១៩៤៧ ។ ច្បាប់ក៏បានកំណត់ផងដែរ ពីសិទ្ធិរបស់ស្ត្រី ដើម្បីឈរឈ្មោះឱ្យគេបោះឆ្នោត ព្រមទាំងឱ្យដឹកនាំ ឬរៀបចំអង្គការមិនមែនរដ្ឋាភិបាល និងគណបក្សនយោបាយ ជាដើម ។

### ៣.៣.២. សមាមាត្រនៃអ្នកបោះឆ្នោតជាស្ត្រី និងអ្នកបោះឆ្នោតជាបុរស :




*ប្រភព: គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត*

### ៣.៣.៣. សមាមាត្រនៃបេក្ខជន និងបេក្ខនារី :

**តួលេខ ៩-សមាមាត្រនៃបេក្ខជន និងបេក្ខនារី :**




*ប្រភព: ក្រសួងមហាផ្ទៃ*

### ៣.៣.៤. សមាមាត្ររវាងភាពដឹកនាំរបស់ស្ត្រី ជាមួយនឹងភាពដឹកនាំរបស់បុរស នៅក្នុងគណបក្ស នយោបាយ :

**តួលេខ ១០. សមាមាត្ររវាងភាពដឹកនាំរបស់ស្ត្រី ជាមួយនឹងភាពដឹកនាំរបស់បុរស នៅក្នុងគណបក្ស នយោបាយ :**




***ប្រភព : ក្រសួងមហាផ្ទៃ***

### ៣.៣.៥. បញ្ហា និងការលំបាករបស់ស្ត្រីក្នុងការចូលរួម នូវគោលនយោបាយបោះឆ្នោត

គ្មានអ្វីដែលរារាំងស្ត្រីមិនចូលរួមការបោះឆ្នោតនេះឡើយ ។ ទោះបីជាយ៉ាងណាក៏ដោយ ស្ត្រីនៅតែមានលទ្ធភាពតិច ក្នុងការទទួលយកព័ត៌មាន ដែលអាចជួយពួកគេឱ្យដឹងអំពីការសំរេចចិត្ត នៅពេលពួក គេធ្វើការបោះឆ្នោត ។

ខាងក្រោមនេះ គឺជាឧបសគ្គខ្លះៗ ចំពោះបេក្ខជនជាស្ត្រី :

- ការចូលរួមក្នុងផ្នែកនយោបាយ ត្រូវបានពិចារណាថា មានគ្រោះថ្នាក់ និងមានអំពើហិង្សា ដូច្នេះ ស្ត្រីត្រូវស្ថិតនៅក្រៅព្រឹត្តការណ៍ ។
- ស្វាមី និងគ្រួសាររបស់ពួកគេ មិនគាំទ្រ ស្ត្រីដែលមានបំណងចង់បានតួនាទី នយោបាយ ពីព្រោះ ពួកគេស្ទើរតែទាំងអស់យល់ថាស្ត្រី គួរតែមានតួនាទីត្រឹមតែជាប្រពន្ធ និងម្តាយ បានហើយ ។
- ស្ត្រីមិនចង់ចំណាយប្រាក់របស់ខ្លួនសំរាប់បេក្ខភាពបោះឆ្នោត
- ស្ត្រីមិនមានបទពិសោធន៍ខាងផ្នែកនយោបាយ
- ស្ត្រីពុំមានទំនុកចិត្ត ដើម្បីដើរតួនាទីជាអ្នកនយោបាយ
- ពុំមានតួនាទីគំរូចំពោះស្ត្រីដែលជាអ្នកដឹកនាំ ផ្នែកនយោបាយ

## ៣.៤ សកម្មភាពសមស្រប

### ១. សកម្មភាពសមស្រប ដើម្បីឱ្យស្ត្រីចូលរួមក្នុងកិច្ចការនយោបាយ:

ក្រសួងកិច្ចការនារី និងអតីតយុទ្ធជនបានធ្វើការតស៊ូមតិ ដើម្បីបញ្ច្រាបយែនឌ័រ នៅក្នុងគោលនយោបាយ ជាតិនិង គោលនយោបាយនៃវិស័យផ្សេងៗ នារីរតនៈ (គោលនយោបាយមួយរបស់ក្រសួង ដើម្បីធ្វើឱ្យ ស្ត្រីមានការរីកចំរើន) ត្រូវបានគេបញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍ សេដ្ឋកិច្ចសង្គមលើកទី២ ឆ្នាំ២០០១- ២០០៥ បញ្ហាស្ត្រីត្រូវបានគេបញ្ចូលក្នុង គោលនយោបាយដ៏សំខាន់នេះ ។

ក្រុមប៉ាន់ប្រមាណ ត្រួតពិនិត្យភាពក្រីក្រ បានបង្កើតឡើងនៅក្នុងក្រសួងផែនការ ដើម្បីត្រួតពិនិត្យ យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ ។ ក្រុមនេះ មានតួនាទីដើម្បីប្រមូលព័ត៌មាន ដែលពុំមាននៅក្នុង ប្រព័ន្ធទិន្នន័យនៃភាពក្រីក្រ ដែលមានស្រាប់ ។

ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន បានទទួលជោគជ័យក្នុងការតស៊ូមតិ ដើម្បីឱ្យមានអនុក្រឹត្យក្នុងការ បង្កើតនូវសកម្មភាពសមស្រប សំរាប់ស្ត្រីថ្នាក់ឃុំ-សង្កាត់ ជាមួយនឹងគណៈកម្មាធិការជាតិ ដើម្បី គាំទ្រក្រុមប្រឹក្សា ឃុំ-សង្កាត់ ។ អនុក្រឹត្យនោះ បានចែងឱ្យស្ត្រី ធ្វើជាប្រធានគណៈកម្មាធិការឃុំ ស្តីពីស្ត្រី និង កុមារ ស្ត្រីត្រូវបានគេចាត់តាំង ប្រសិនជាក្រុមប្រឹក្សាឃុំ-សង្កាត់ណាមួយ ពុំមានសមាជិកជាស្ត្រីអនុក្រឹត្យនេះ ត្រូវបានគេអនុវត្តប្រកបដោយជោគជ័យមួយចំនួនធំ ។

ក្រុមប្រឹក្សាជាតិរបស់ស្ត្រី ត្រូវបានគេបង្កើតឡើង ដោយរដ្ឋាភិបាលនៅឆ្នាំ២០០១ ហើយក្រុម ប្រឹក្សានេះជាអ្នកទទួលខុសត្រូវ ក្នុងការសរសេររបាយការណ៍របស់ប្រទេសកម្ពុជា អំពីសន្ធិសញ្ញាលុប បំបាត់ការរើសអើងគ្រប់រូបភាពទៅលើស្ត្រី **(Country CEDAW report )** ក្រុមប្រឹក្សានេះ បានចែកចាយ ឯកសារចម្លងទៅកម្រិត ខេត្ត-ភូមិ ។ ទោះបីជាយ៉ាងណាក៏ដោយ ការងារទាំងឡាយនេះ មិនទាន់គ្រប់គ្រាន់ ដើម្បីឱ្យមានការផ្លាស់ប្តូរដ៏កំភួនទៅលើស្ថានភាពឡើយ ។ ច្បាប់ស្តីពីអំពើហឹង្សាក្នុងគ្រួសារ ត្រូវបានអនុម័ត ដោយក្រុមប្រឹក្សារដ្ឋមន្ត្រី ឥឡូវនេះ សេចក្តីព្រាងនេះ ស្ថិតនៅក្នុងរដ្ឋសភា ។ ឥឡូវនេះ រដ្ឋសភា ទំនងជា អនុម័តច្បាប់នេះ ក្នុងពេលឆាប់ៗខាងមុខនេះ ។ ច្បាប់នេះ មានការជំទាស់ភាគច្រើនពីរដ្ឋសភា ដោយសារ ខ្វះការយល់ដឹងជាទូទៅទៅលើនេះ។

**<u>សកម្មភាពសមស្រប សំរាប់ស្ត្រី នៅក្នុងរដ្ឋាភិបាល :</u>**

គេពុំទាន់ឃើញមានវិធានការដាក់លាក់ណាមួយសមស្របសំរាប់ជួយស្ត្រី នៅក្នុងរដ្ឋាភិបាលឡើយ ផែនការសកម្មភាពរបស់រដ្ឋាភិបាល (ផែនការកែទម្រង់រដ្ឋបាល ) បានបញ្ចូលនូវបញ្ហាយែនឌ័រ ជាសន្ទស្សន៍ សំរាប់ការត្រួតពិនិត្យ ។ ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល បានទទួលយកគោលការណ៍កូតានៅក្នុងការលើក តម្កើងស្ត្រី ប៉ុន្តែមកទល់បច្ចុប្បន្ននេះ វាមានការរីកចំរើនតិចតួចណាស់ ។

**គោលនយោបាយយាយីផ្លូវភេទៈ** ពុំមានវិធានការជាក់លាក់ណាមួយឡើយ ។

**បទពិសោធន៍ក្នុងការអនុវត្តន៍គោលនយោបាយៈ**

ពុំទាន់មានការអនុវត្តន៍ណាមួយ ទាក់ទងទៅនឹងគោលនយោបាយមធ្យោបាយសមស្របនេះឡើយ ។ មានការពិភាក្សាជាច្រើន និងការប្តេជ្ញាចិត្ត ដោយផ្ទាល់មាត់ ប៉ុន្តែមកទល់នឹងបច្ចុប្បន្ននេះ មានការផ្លាស់ប្តូរតិចតួចណាស់ ក្នុងការចាប់ផ្តើមធ្វើសកម្មភាពសមស្របនេះ ដើម្បីលើកតម្កើងស្ត្រី ។

## ៣.៥. ក្រុមស្ត្រី ដែលត្រូវគេរើសអើង

### ៣.៥.១ ស្ត្រីក្នុងជម្លោះប្រដាប់អាវុធៈ

ស្ត្រីមានតួនាទីសំខាន់ នៅក្នុងកម្មវិធីកាត់បន្ថយអាវុធ ។ ពួកគេហាក់ដូចជា មានការតស៊ូមតិខ្លាំង នៅក្នុងការបញ្ចុះបញ្ចូលសំរាប់កម្មវិធី ។ ពួកគេនឹងធ្វើការជាមួយកម្មវិធី និងអាជ្ញាធរក្នុងស្រុក ដើម្បីប្រគល់អាវុធទាំងនេះ ទៅសហគមន៏វិញ ហើយបន្ទាប់មកប្រគល់ឱ្យអាជ្ញាធរក្នុងស្រុក ចាប់តាំងពីបានបញ្ជូនមក ឱ្យពួកគេជាមនុស្សដែលបានយល់ពីរបៀបរក្សាសន្តិភាពនៅក្នុងគ្រួសារ និងនៅក្នុងសហគមន៏ ។ អាជ្ញាធរ ក្នុងស្រុក និងកម្មវិធីបង្រួបបង្រួម ដែលទទួលស្គាល់ថា ការចូលរួមរបស់ស្ត្រីនៅក្នុងកម្មវិធី គឺមានសារៈសំខាន់ ណាស់សំរាប់ការទទួលជោគជ័យក្នុងកម្មវិធី ។ តាមការស្ទាបស្ទង់ នាពេលថ្មីៗនេះ បង្ហាញថា បុរស ៥០ % និងនារី ៧០ % នៅតំបន់ជនបទ ត្រូវបានពាក់ព័ន្ធនៅក្នុងកម្មវិធីកាត់បន្ថយអាវុធ ។ ទោះបី ជាយ៉ាងណាក៏ដោយ ។ នៅក្នុងទីក្រុង ការចូលរួមរបស់ស្ត្រីធ្លាក់ចុះដល់ ៥០ % ។ ការស្ទាបស្ទង់រកឃើញ ថា ស្ត្រីដើរតួនាទីសំខាន់ជាអ្នកបង្កើតសន្តិសុខ និងជាអ្នកសម្របសម្រួលជម្លោះ ។

### ៣.៥.២. អំពើហឹង្សាប្រឆាំងនឹងស្ត្រីៈ

មានអំពើហឹង្សាជាច្រើនរូបភាពដែលកើតឡើងនៅក្នុងប្រទេសកម្ពុជា ។ ការជួញដូរ គឺអំពើហឹង្សា ដែលព្រៃផ្សៃបំផុត ចំពោះសិទ្ធិរបស់ពួកគេ ។ តាមការប៉ាន់ប្រមាណមានស្ត្រី និងកុមារប្រមាណ ១០០. ០០០នាក់ ត្រូវបានគេធ្វើការជួញដូរ និងចំនួនដែលបានដឹងពីការជួញដូរឱ្យបំរើការងារផ្លូវភេទនេះ។ នៅទី ក្រុងភ្នំពេញតែមួយកន្លែង មាននារីបំរើផ្លូវភេទ ដែលមិនទាន់គ្រប់អាយុដល់ទៅ ៥០០០ នាក់ ។ មាន ៤៧ % នៃស្ត្រីបំរើផ្លូវភេទទាំងនោះ ត្រូវបានគេបោកប្រាស់ និងលក់ឱ្យទៅបំរើផ្លូវភេទ ។

ស្ត្រីខ្លះ ដែលជាជនរងគ្រោះ ដោយការបំពាននេះ គ្មានមធ្យោបាយ ដើម្បីគេចចេញពីកន្លែងដែលគេចាប់ចិញ្ចឹមនោះទេ ។ ពួកគេមានជំរើសតិចតួចណាស់ ។ នៅក្នុងការអង្កេតនាឆ្នាំ ២០០០ របស់អង្គការ សាដ (CADHS) មានស្ត្រី២នាក់ក្នុងចំណោម ៥នាក់ គ្មានអ្នកជួយពួកគេផ្នែកហិរញ្ញវត្ថុទេ ប្រសិនបើពួកគេសំរេចចិត្តចាក ចេញពីស្ថានភាពហឹង្សានេះ ។

### ៣.៥.៣ ការពិភាក្សាលើគោលនយោបាយ និងការអនុវត្តន៍:

បញ្ហាការជួញដូរស្ត្រី បានបង្កឱ្យមានភាពស្មុគស្មាញ ដោយសារជនរងគ្រោះ មានភាពក្រីក្រ និងភាព ធូររលុង របស់ច្បាប់ អំពើរពុករលួយរបស់អ្នកប្រតិបត្តិច្បាប់ និងទំលាប់នៃការរើសអើងយេនឌ័រ។ ស្ត្រីដែល ទទួលរង នូវអំពើជួញដូរ ត្រូវរងនូវការមិនពេញចិត្តពីសហគមន៍ ឬប្រជាពលរដ្ឋ នៅពេលដែលពួកគេត្រឡប់ ទៅផ្ទះវិញ ។

អាជ្ញាធរ និងប្រព័ន្ធច្បាប់នៅប្រទេសកម្ពុជា ចាត់ទុកការជួញដូរក្មេងស្រី ជាអំពើល្មើសច្បាប់ ដែលបានបង្ហាញ ដោយករណីក្មេងស្រីជនជាតិវៀតណាម ១៤ នាក់ ពីបទល្មើសអន្តោប្រវេសន៍ ដែលត្រូវបានជាប់ពាក់ព័ន្ធ នៅក្នុងការឆ្នក់សង្គ្រោះ កាលពីខែ មិថុនា ឆ្នាំ ២០០២ ។

អំពើហឹង្សាក្នុងគ្រួសារ គឺជាសកម្មភាពព្រហ្មទ័ណ្ឌ ក្រោមរចនាសម្ព័ន្ធច្បាប់នាពេលថ្មីៗនេះ។ ទោះបីជា យ៉ាងណាក៏ដោយ ក៏មានស្ត្រីតិចតួចប៉ុណ្ណោះ ដែលមានបំណងឱ្យប្តីរបស់ពួកគេ ទៅតុលាការ ពីព្រោះថា ពួកគេ មិន មានសមត្ថភាព ដើម្បីបង់ប្រាក់សំរាប់ការតវ៉ាតាមផ្លូវច្បាប់នោះឡើយ ។

**បញ្ជីរាយនាមឈ្មោះអ្នកដែលបានសម្ភាស៍**

| លេខ | ឈ្មោះ | ភេទ | តួនាទី | ស្ថាប័ន |
|---|---|---|---|---|
| ១ | លោកស្រី ប៉ុក ណណ្តា | ស្រី | នាយកប្រតិបត្តិ | អង្គការចំរើនស្ត្រី |
| ២ | លោកស្រី ឯក សុផាន់ណា | ស្រី | អ្នកសំរបសំរួលផ្នែកយេនឌ័រ និង អភិវឌ្ឍន៍ | វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល |
| ៣ | លោកជំទាវ គុយ វេទ | ស្រី | សមាជិកនៃគណៈកម្មការជាតិ រៀបចំការបោះឆ្នោត | គណៈកម្មការជាតិរៀបចំការបោះឆ្នោត និង មជ្ឈមណ្ឌលនៃសំលេងស្ត្រីខ្មែរ |
| ៤ | លោក សេង ផល្លី | ប្រុស | នាយកប្រតិបត្តិ | អង្គការពលកម្មខ្មែរ |
| ៥ | លោកស្រី រស់ សុភាព | ស្រី | នាយកប្រតិបត្តិ | អង្គការយេនឌ័រ និង អភិវឌ្ឍន៍ |
| ៦ | លោកស្រី លឹម មុនី | ស្រី | ប្រធានផ្នែកស្ត្រី | អង្គការ ADHOC |
| ៧ | លោកស្រី យឹម នីណូឡា | ស្រី | នាយកប្រតិបត្តិ | អង្គការ KWVC |
| ៨ | លោកស្រី អ៊ុង ចាន់ថុល | ស្រី | នាយកប្រតិបត្តិ | មជ្ឈមណ្ឌលស្ត្រីកម្ពុជាមានវិបត្តិ |
| ៩ | លោកស្រី ញឹក អូន | ស្រី | សមាជិកក្រុមប្រឹក្សាឃុំ | |
| ១០ | លោកស្រី ហេង គីម | ស្រី | សមាជិកក្រុមប្រឹក្សាឃុំ | |
| ១១ | លោកស្រី ភាន់ សារីម | ស្រី | សមាជិកក្រុមប្រឹក្សាឃុំ | |
| ១២ | លោកស្រី គុណ វ៉ាន់ | ស្រី | ជំទប់ទី២នៃក្រុមប្រឹក្សាឃុំ | |
| ១៣ | លោក ផាន់ ផាត | ប្រុស | ជំទប់នៃក្រុមប្រឹក្សាឃុំ | |
| ១៤ | លោក អាត សុផាត | ប្រុស | ស្មៀនឃុំ | |

## References

Gender and Development for Cambodia, 2000. *“Gender in Election and Female Leadership at the Communal level”*

Gender and Development for Cambodia, January 2004. *“Commune Councils & Civil Society”*

Gender and Development for Cambodia, December 2003.*“Draft on Cambodia Country Gender Assessment for National and Provincial Consultation Workshop”*

Royal Government of Cambodia, 2001. *“Elimination of all forms of Discrimination against Women in Cambodia”*

Royal Government of Cambodia, October 2003. *“National Report on the Implementation of the International Convention on Elimination of all Forms of Discrimination against Women in Cambodia”*

Gender in Development, July 2001. *“Gender Watch”*

Women for Prosperity, May 2003. *“Women and Election”*

Cambodian labor Organization-CLO, February 2004. *“Report On Work Conditions for 2003 to Improve Textile and Shoe Industry”*

National Election Committee, February 2002. *“Report on the Commune Council Elections”*

Comfrel, March 2002. *“Working to Strengthen and Expand Democracy Worldwide”*

A collaboration between UNIFEM, The world Bank, ADB,UNDP, DFID/UK and the Ministry of women’s and Veterans’ Affairs, April 2004. *“A fair share for women Cambodia Gender Assessment”*

Ministry of Planning Royal Cambodian Government, November 2003. *“Cambodia Millennium Development Goals Report”*